រឿង

# ក្រមុំខ្វាអ_ក កម្លោះស្លូឈាប

ដោយ

ហាក់-ឆៃហុក

សមាជិកសមាគមអ្នកនិពន្ធខ្មែរ

ប្រលោមលោកក្នុងមនោសញ្ចេតនា

ការផ្សាយរបស់

ផន្ទកោសីយ៍លេខ៥៦ ទល់មុខរោងភាពយន្តសូរិយា ភ្នំពេញ

( មានដាក់លក់ដុំ នៅរោងពុម្ពវិរិយៈ ភ្នំពេញ)

រក្សាសិទ្ធ

ព.ស.២៧០៨ គ.ស.១៩៦៥

បោះពុម្ពឡើងវិញដោយបណ្ណាគារ "អង្គរធំ"

អាសយដ្ឋាន: ១៤៩អឺសូឡែ, វិថីខេមរភូមិន្ទ, ភ្នំពេញ

ទូរស័ព្ទលេខៈ (៨៥៥) ២៣ ២១០ ២៥៨
ឆ្នាំ ២០០២
(បោះពុម្ពក្នុងខ្នាតៈ ២០ ខ ១៤ សង់ទីម៉ែត្រ)
រូបក្របៈ គូរឡើងវិញដោយវិចិត្រករ សែន សាមន្តតារា
(គូរតាមរូបដើម)
វាយអត្ថបទដោយកញ្ញា ហេង គឹមសេង
ម៉ូតអក្សរ ឡិម្យនរ្យេ ទំហំ ២២
រចនាជាសៀវភៅដោយលោក ហាក់ វ៉ាន់ដារា
កែអក្ខរាវិរុទ្ធដោយលោក ទុំ សារីម
ឯកសារដើមបានមកពីគម្រោងស្រាវជ្រាវ
*"វិវឌ្ឍន៍អក្សរសិល្ប៍ខ្មែរសតវត្សទី២០"*

# អារម្ភកថា

ស្លាកស្នាមប្រវត្តិសាស្ត្រជាច្រើនបានបង្ហាញឱ្យឃើញថា ជនជាតិខ្មែរជាជនជាតិមួយមានខឿនអរិយធម៌-វប្បធម៌ដ៏រុងរឿង។ ទោះបីជាមានការរុកទន្រ្ទានពីសត្រូវជិតខាងឬមានចំបាំងរាំងជល់ផ្ទៃក្នុងក៏ដោយ ក៏វិស័យសិល្បៈ-អក្សរសិល្ប៍របស់ខ្លួន នៅតែបន្តការវិវត្តន៍ឥតឈប់ឈរ។ ប៉ុន្តែគួរឱ្យអនិច្ចាឆ្នាំ ១៩៧០ រដ្ឋប្រហារមួយបានទម្លាក់ព្រះមហាក្សត្រព្រះបាទ សម្ដេចព្រះ *នរោ*

*ត្តមសីហនុ* ដែលព្រះអង្គតែងយកព្រះទ័យទុកដាក់លើវិស័យអក្សរសាស្ត្រជាតិ រហូតប្រជាពលរដ្ឋបានថ្វាយព្រះនាមព្រះអង្គ ជាព្រះបិតាអក្សរសាស្ត្រជាតិ ។ សង្គ្រាម, របបប្រល័យពូជសាសន៍ បានបំផ្លិចបំផ្លាញជាតិគ្រប់វិស័យស្ទើរដល់កម្រិតសូន្យក្នុងនោះមានស្នាដៃអក្សរសិល្ប៍ផងដែរ។ ក្រោយពីមានការបង្រួបបង្រួមជាតិក្រោមព្រះរាជកិច្ចដឹកនាំរបស់ព្រះមហាក្សត្រ ជនជាតិខ្មែរបានរួបរួមសាមគ្គីគ្នាជាធ្លុងមួយស្ដារ និងកសាងជាតិឡើងវិញ ។ ដោយយល់ឃើញពីសារៈសំខាន់នៃវិស័យអក្សរសិល្ប៍ក្នុងការលើកស្ទួយវប្បធមិរបស់ខ្លួន បណ្ណាគារ "អង្គរធំ" យើងខ្ញុំក៏បានសម្រេចលើកយកស្នាដៃប្រលោមលោកចាស់ៗ របស់អ្នកនិពន្ធដែលធ្លាប់មានឈ្មោះល្បី មកធ្វើការបោះពុម្ពឡើងវិញ ក្នុងគោលបំណងថែរក្សានូវសម្បត្តិរួមរបស់ជាតិ ដើម្បីឱ្យកូនខ្មែរជំនាន់ក្រោយៗ បានចេះដឹងគ្រាន់ជាគុណប្រយោជន៏រួមដល់សង្គមជាតិ ។

*ភ្នំពេញ, ថ្ងៃទី ០៧ ខែតុលា ឆ្នាំ ២០០២*

១

# អារម្ភបទ

អស់លោកអ្នកនាងជាទីគោរព ...

ក្រោយពីអស់លោកអ្នកនាងកញ្ញា បានអានរឿងជីវិតសោកសៅ, រន្ធត់ឈឺចាប់,ទុក្ខព្រួយស្រក់ទឹកភ្នែក,របស់អ្នកនិពន្ធខ្ញុំជាច្រើន រឿងមកហើយដូចជារឿង ប្រុសអប្រិយ៍ស្រីរងកម្ម, ឱ!ផ្សែងមរណៈ,ផុតអនាគតរលត់ក្តីស្នេហ៍។ម្តងនេះ អ្នកនិពន្ធ សូមផ្លាស់អារម្មណ៍អស់ លោកអ្នកអាននាងកញ្ញា ឱ្យមកពើបប្រទះរសជាតិថ្មីគឺរឿងស្នេហា កំប្លែងរវាងក្រមុំកម្លោះស្រុកស្រែ ដែលមានចំណងជើងថា : ក្រមុំខ្លាកកម្លោះស្លឈាម !

រឿងក្រមុំខ្លារក កម្លោះស្លឈាម មិនមែនជារឿងអាសអាភាស ឬជារឿងនាំឱ្យសតិអារម្មណ៍យុវជនយុវនារីលង់ទៅក្នុងសមុទ្រអបាយមុខទេ ហើយក៏មិនមែនជាក្បួនទូន្មានមានឥទ្ធិពលអ្វី បង្គាប់បញ្ជាលើ មនោសញ្ចេតនារបស់អ្នកអានទូទៅក៏ទេដែរ ។

រឿងក្រមុំខ្លារក កម្លោះស្លឈាម ជារឿងកំប្លែងដែលអ្នកនិពន្ធ ប្រឌិតឡើងដោយសុទ្ធសាធ ដើម្បីជាជំនួយក្រោយពេលប្រកបការងារហត់នឿយរបស់អស់លោកអ្នកនាងកញ្ញាឱ្យអានហើយសើចសប្បាយចិត្ត បន្ធូរទុក្ខព្រួយបន្ធូរអារម្មណ៍សៅហ្មងតែប៉ុណ្ណោះ ។ ដូច្នេះ អ្នកនិពន្ធខ្ញុំសូមផ្ញើសេចក្តីសង្ឃឹមថា រឿងក្រមុំខ្លារកកម្លោះស្លឈាមអាចក្លាយទៅជាមិត្តដ៏ល្អប្រចាំទូបណ្តាល័យអស់លោកអ្នកនាងកញ្ញាជាពុំខាន ។

ភ្នំពេញ ថ្ងៃទី៤ ខែតុលា ឆ្នាំ១៩៦៥

អ្នកនិពន្ធ

ហាក់-ឆៃហុក

-១-

ព្រោះតែភ្លេងកន្ទ្រឹមក្រហម

ឮសូរភ្លេងការកន្ទ្រឹមក្រហម ក្រមុំអត់ទ្រាំទប់ពុំបាន
ស្រៀវស្រាញស្រួលស្រើបរសើបប្រាណ តណ្ហារុញច្រានចង់បានប្ដី ។
ខ្យល់ខែកត្ដិកបក់ត្រសៀក រហើយទ្រគាកប៉ុនតិចអី
ត្រជាក់ជិតដល់គល់ភ្លៅស្រី ម៉ែអើយរកប្ដីឱ្យវៃមក ។

នៅតាមដងផ្លូវជាតិលេខ៥ ចន្លោះពីឃុំក្រឡាញភ្លុកទៅស្រុក មោងឫស្សី ក្នុងទឹរួមខេត្តបាត់ដំបង មានឃុំមួយឈ្មោះឃុំព្រៃស្វាយ។ ឃុំនេះ កាលនៅក្នុងកំឡុងអាណាព្យាបាលរាជការបារាំងសែស មានសភាពដុនដាប អ្នកស្រុកក្រីក្រ ផ្ទះសំបែងធ្លុះធ្លាយរយីករយាក អ្នកទេសចរណ៍មិនដែលអើពើ ហើយអ្នកខ្លះមិនទាំងស្គាល់ឃុំនេះផង ។

លុះមកដល់ស្រុកទេសបានសានត្រាន ប្រទេសឯករាជ្យ គឺក្នុងសម័យសង្គមរាស្ត្រនិយម ដែលមានអង្គសម្ដេចឪជាទីស្នេហារបស់ ប្រជាជនខ្មែរ ៩៩%

ឡើងធ្វើជាប្រធាន។ ឃុំព្រៃស្វាយក៏ផ្លាស់ផ្លោលពីគំនរ ហិនភាពទៅកាន់វឌ្ឍនភាពយ៉ាងរហ័ស។ ផ្ទះអ្នកស្រុកលាចាកសភាពដើម ទៅជាផ្ទះឈើខ្លះ ផ្ទះឥដ្ឋខ្លះ ។ អ្នកស្រុកលែងភ័យភិតពីចោរកម្ហូញ រកស៊ីមានបានសម្បូណ៌សប្បាយដូចជាខេត្តនានា ក្នុងព្រះរាជអាណាចក្រដែរ ។

ថ្ងៃនេះ ផ្ទះមេស្រុកគាំ គេញតែសូរមេក្រូចាក់បទភ្លេងកន្សែង ក្រហមព្ញរងំតាំងពីព្រលឹម រីឯអ្នកស្រុកជាភ្ញៀវជាញាតិសាច់សាលោហិតជិតឆ្ងាយ គេនាំគ្នាមកកាន់ផ្ទះគាត់កកកុញជាលំដាប់។ មែនហើយ ថ្ងៃនេះជាថ្ងៃនក្ខត្តឫក្សជាថ្ងៃការកូនក្រមុំគាត់ឈ្មោះនាងរ៉ន ឱ្យទៅអាអន្ទិតសនទើបនឹងសិកលាស់សក់ខ្ចីបានប៉ុនថ្នាំងដៃ។ ក្រមុំកម្លោះដែល ត្រូវជាមិត្តភ័ក្ត្រខាងអន្ទិតសន ខាងនាងរ៉ននាំគ្នាតែងកាយស្រស់កុំផាន ផាត់ម្សៅលាបក្រែមមាត់ ប្រួចទឹកអប់អូកូឡូញ (Eau de Cologne) ដើរជាជួរសំដៅទៅបន្ទិតអន្ទិតសន និងបន្ទប់នាង រ៉ន ។ ដើម្បីមកជួយ កំដរកូនក្រមុំកូនកម្លោះ ដែលជាទំនៀមទំលាប់ប្រពៃណីបុរាណមាន ជាប់យូរយារតាំងពីជីដូនជីតាជីលួតជីលាមកម្ល៉េះ ។

អន្ទិតសនកូនកម្លោះ ស្លៀកចងក្បិនផាមួងពណ៌កទាអាវសែ សយប៉ាក់ឱន ពាក់វ៉ែនតាខ្មៅក្អែកក្របីហើយមានពាក់ឈៀងខ្សែកប៊ុន ខ្សែគោ (ខ្សែកបូរាណសំរាប់ពិធីរៀបមង្គលការ ) បីខ្សែ បន្តោងកូន អង្គាំតូចៗ ភ្លឺះផ្លេកៗជុំវិញចង្កេះ។ រីឯនាងរ៉នក៏តែងខ្លួនមិនចាញ់កូនកម្លោះដែរ នាងស្លៀកសំពត់ចរបាប់ពណ៌ព្រីងទុំ ព័ទ្ធស្បៃពណ៌លឿង ជុំវិញទ្រូងជំនួសអាវនៅក ពាក់ខ្សែមាសអង្គាំបន្តោងត្បូងបរប៉ៃលិនចំរុះ ពណ៌ភ្លឺផ្លេកៗដេញពន្លឺថ្ងៃ ត្រចៀកសៀតអាវមាសទឹកដប់ក្រហមឆ្អៅ។ ភ្ញៀវចាស់ទុំក្រមុំកម្លោះមេម៉ាយ សៅកែ នាំគ្នា

ជញ្ជក់មាត់សម្លក់សម្លឹង លួចសរសើរន្ទូវសម្រស់កូនក្រមុំ កូនកម្លោះគ្រប់ៗគ្នា។ អន្ទិតសន និង នាង៉រនពេលនេះស្អាតមិនខុសអ្វីពីព្រះឥន្ទ្រ និងនាងសុជាតា អាចជាច្យុត ចុះពីឋានតាវតឹង្សឡើយ ខុសបន្តិចត្រង់អន្ទិតសនសក់ដុះមិនទាន់វែង រកញែកភ្លីតាំងហ្គោមិនបាន កុំអីភ្លូកទឹកភ្លូកដីហើយព្រៃស្វាយថ្ងៃនេះ ។

...........................................................

ព្រះអាទិត្យចរលីលាគ្រឿនៗ ត្រឡប់ចូលគុហាមរណៈ បន្ទាប់មកស្លែខ្មៅនៃធម្មជាតិក៏គ្របដណ្តប់គ្រប់ភពផែនដែនដី។ រាត្រីខាង រនោចប្រាសចាកដួងចន្ទមានតែពន្លឺផ្កាយកូនមាន់, ផ្កាយចោរ ចោល កំទេច រស្មីព្រិចៗមកលើពិភពលោក ។ខ្យល់រងាររខែកត្តិកបក់ផាយផាត់ ប៉ះស្លឹកខ្លុងរណ្តំគ្នាឮសូររ៉ាវ ! រ៉ាវ ! ដូចសម្លេងថ្ងូចថ្ងូរនៃក្រមុំកម្លោះ មិនទាន់មានគូស្រករលាយឡំនឹងសម្លេងភ្លេងកន្សែងក្រហមនៅផ្ទះ មេស្រុកគាំ អណ្តែតលឿនលយ តាមរលកធាតុអាកាសទៅបើកទ្វារបេះ ដូងនរៈនារី ឱ្យស្ទុះពុះកញ្ជ្រោលរលាករលួយប្រាណ ត្រូវសណ្តំក្នុងមន្តស្នេហ៍នេះតែម្តង ។

ទឹកសន្សើមធ្លាក់ចុះលើដំបូលផ្ទះស្លឹកឮសូរស្រឹប ! ស្រឹប ! ដូច ស៊ីរបជើងមនុស្សដើរ ។ ផ្ទះពូញៀមមីងឡឹកស្ងាត់ច្រៀប ។ ចង្រៀងប្រេងកាត ចោលពន្លឺផ្លុងៗ ភ្លឹបភ្លែតៗ រកកលចង់រលត់កាលបើត្រូវខ្យល់បក់កញ្ជ្រោលខ្លាំងម្តងៗ ។

នាងធឿន តាំងពីត្រឡប់មកពីជួយបំពេញកុសលបុណ្យបញ្ចុះ គោលអាអន្ទិតសននាង៉រន ក៏ចូលទៅប្រាសខ្លួនដេកក្នុងបន្ទប់ យកដៃគងថ្ងាសសន្ទឹងសន្ទៃមិនខ្ជីរវីរវល់អើពើនឹងបាយទឹក ។ដេកបើកភ្នែកភ្លឹះៗសម្លឹង មើលទៅ

ដំបូលមុង ត្រចៀកប្រុងចាំស្តាប់ភ្លេងការកន្ទ្រេងក្រហម ជួនកាលប្រែខ្លួនរសាប់រសល់ បែរទៅឆ្វេង ងាកស្តាំ ក្រញីសក់ខ្លួនឯង ធាក់ភួយខ្មៅឱបធ្លាក់ទៅក្រោមគ្រែរតាត់រតាយ សំពត់ស្លៀកជាប់នឹង ខ្លួនរបូតរលូតមកនៅលើដើមទ្រូងទាំងអស់ ។ មួយសន្ទុះក្រោយមក នាងធឿនក៏ស្រាប់តែញញឹមម្នាក់ឯង ថ្ពាល់ទាំងគូឡើងសរសៃឈាមក្រហមព្រឿងៗដូចផ្កាកុលាបទើបនឹងរីក។ ស្ទុះក្រោកទៅប្រមូលភួយ ខ្មៅឱបមកដាក់លើគ្រែវិញ ហើយនាងក៏ឡើងជិះលើខ្មៅឱបរុញញ័រៗ ទៅមុខដូចជាគេបំផាយសេះបានមួយសន្ទុះ ស្រាប់តែផ្ងារទៅក្រោយ ដួលដេកស្រប៉ាបក្រោកលែងរួច ទាញភួយមកគ្របគ្រលំជិត តាំងពីក្បាលរហូតដល់ចុងជើង ផុតពីហ្នឹងក៏ដេកយំសសឹកអួលអាក់ ហាក់ដូចជានរណាគេមកសំពងចំកណ្ដាលក្បាលបួនដប់អន្លូងរួចទៅហើយ ។

មីងឡឹក ឮសូរសម្លេងកូនយំ នឹកចម្លែកផ្អែកក្នុងចិត្ត ខំផ្ទៀងត្រចៀកដាក់ផ្ទាប់ជញ្ជាំង លុះដឹងជាក់ជាសម្លេងនាងធឿន គាត់ក៏ប្រែខ្លួនងាកទៅដាស់ពូញៅ ដែលកំពុងលង់លក់ស្រម៉ុក ខ... !ខ...!យ៉ាង សែនសុខ :

-ពុកវ៉ា ! នែ ...! ពុកវ៉ា !

-ស្អីទៀតហើយហ្អា ! ក្រោកឡើងមើល៍

-រកតែអញដេកពួនមិនបាន ...!

ពូញៅ ប្រែខ្លួនមកស្រែកគំរាមដាក់មីងឡឹកទាំងខ្លួនឯងនៅបិទភ្នែកជិត ។

-យី ! គាត់នេះដេកទ្រមក់ម្លេះ ! ក្រោកឡើង !

មីងឡឹក ចាប់អង្រួនខ្លួនប្ដីយកពីខាងឈ្នះដៃ ទ្រាំមិនបាន ពូញៀ ក៏ក្រោកអង្គុយ សក់ក្បាលសើងមមើង សួរទៅប្រពន្ធថា :

-រឿងស្អីហ៎ះ !

-ពុកវាឯងមិនស្ដាប់មើល៍ ! ឮសម្លេងមីកាធឿនវាយំទេ ?

ពូញៀ ផ្ទៀងត្រចៀកស្ដាប់មួយសន្ទុះ ក៏ងាកមកងក់ក្បាលដាក់ប្រពន្ធ :

-អ៊ឹម៎ ! វាយំមែន ...តើវាយំរឿងអីហ្នំ? ពីថ្ងៃត្រឡប់មកពីជួយបុណ្យ ការកូនលោកមេស្រុកគាំវិញ ឃើញទឹកមុខវាស្រស់បស់ ទេតើ ?

-ប្រហែលជាវាឈឺធ្មេញហើយមើលទៅ ...

-អើ ! យើងនាំគ្នាទៅមើលវាបន្តិចមើល៍ !

-ថាហើយ ពូញៀក៏ទាញដៃមីងឡឹកក្រោកដើរត្រុនៗ សំដៅទៅបន្ទប់នាងធឿនកូនស្រីបណ្ដូលចិត្តរបស់គាត់ ។

នាងធឿនដេកយំ ហ៊ុ ! ហ៊ុ! ទទូរភ្ជួយជិតពុំបានដឹងខ្លួនថាមានគេចូលមកក្នុងបន្ទប់ទេ លុះមានដៃត្រជាក់ៗមកលូកស្ទាបថ្ងាស នឹកស្មានថាខ្មោចកម្លោះលងក៏ស្រែកយ៉ៃ! ភ្ញាក់ធាក់មួយជើងប៉ុងចំកណ្ដាលដើមទ្រូងពូញៀ ខ្ទាតទៅដេកថ្ងូររហ៊ឹមនៅគៀនជញ្ជាំង ។

មីងឡឹកស្ទុះទៅឱបជើងកូនក្រមុំទាំងពីរជាប់ ក្រែងត្រូវរង្វាន់ ដូចប្ដីគាត់ទៀត :

-វាយ៉ាងម៉េចកាធឿន ! ហងខ្មោចចូលទេឬ?

នាងធឿន ស្គាល់ជាក់សម្លេងម្ដាយ ស្ទុះក្រោកអង្គុយ បើកភ្នែកធំៗ លើកដៃប្រណម្យនិយាយញ័រមាត់ប៉ប៉ិបប៉ប៉ុបថា :

-ចាំ ... ម៉ែ ...! ខ្ញុំ ...វា...ខ្ញុំ អូ ! អំបាញ់មិញខ្ញុំធាក់ត្រូវ ពុកឬ ?

នាងធឿនចុះពីលើគ្រែបំរុងទៅជួយលើកឪពុក តែពូញៀវរាដៃ ខំប្រឹងក្រោកខ្លួនឯង ។

-មិនចាំបាច់មកជួយលើកអញទេ ! អញក្រោកខ្លួនអញបាន ហើយ ...!

នាងធឿនដើរមកអង្គុយបត់ជើងលើគ្រែវិញ។ មីងឡឹកសួរទៅទៀតៈ

-ក្នុងខ្លួនឯងវាយ៉ាងម៉េច បានប្រកាច់ខ្លាំងដៃម្ល៉េះ ហើយដេកយំ រឿងអី ប្រាប់អញមកមើល៍ ?

-ចាំ ម៉ែ ... ម៉ែឮមេក្រូផ្ទះអ៊ុំគាំ គេចាក់ភ្លេងការបទកន្សែងក្រហមទេ ?

-ចឹអញមិនឮ ! ភ្លេងនឹងវាជាប់ទាក់ទងអីដល់ឯង ?

នាងធឿន អេះអុញអល់អែករារែកក្នុងចិត្តមិនចង់ហ៊ានស្ដី តែមកនឹកឃើញរឿងកាលពីថ្ងៃ ក៏ប្រថុយកាត់កើ្ដកាត់ខ្មាស់ជំរាបទៅម្ដាយ ថា :

-ខ្ញុំឃើញគេមានប្ដីដូចជាសប្បាយណាស់ម៉ែ ទ្រគាកគេរីកបែកសាច់បែកឈាមឡើងថ្លាស្រស់ ដើមទ្រូងក្រពុង ស្លៀកហ្ស៊ីប (Jupe) ពាក់អាវម៉ូដ (Mode) សមណាស់ ! មើល ! មីសឿន, មីវ៉ាណេ, មីកឹម, មីរ៉ន, សុទ្ធតែក្រមុំភូមិយើងគេមានប្ដីបានសប្បាយអស់ទៅហើយ ចុះត្រង់រូបខ្ញុំមួយ ក៏នៅសល់

យូរជាងគេជាងឯងម្លេះ!ខ្ញុំចង់បានប្តីនឹងគេ ណាស់ម៉ែតែផុតខែកត្តិកនេះទៀត... ប្រេះទ្រូងស្លាប់ហើយខ្ញុំ ...

និយាយចប់ ទឹកភ្នែកចង់បានប្តី ក៏ស្រក់តក់ៗ ដូចតំណក់ទឹករមៀល លើស្លឹកឈូក ។

ពូញ៉ៅ គ្រវីក្បាលញ៉ូរតគាត់យកដៃតប់ថ្ងាសខ្លួនឯងលាន់ប៉ូក ! ប៉ូក! គាត់នឹកឆ្អែតចិត្តឆ្អិតឱរានឹងសំដីកូនក្រមុំ។ ចំណែកមីងឡឹកគាត់ភ្ញាក់ នឹងសំដីកូនបញ្ឈរភ្នែកស្លឹងហៀរទឹកមាត់ស្លាចេញមកដោយពុំដឹងខ្លួន។

ពូញ៉ៅ អង្គុយភាន់ភាំងមួយស្របក់ ក៏សួរទៅនាងធឿនទាំងទឹកមុខក្រៀមក្រោះថា :

-អូ ! ឯងយំហ្នឹង យំចង់បានប្តីទេ ?

-ចាំ ! ត្រូវហើយពុក ខ្ញុំយំចង់បានប្តី !

-ហ៊ឺ ! ស្លាប់ហើយអញមួយជាន់នេះ( ពូញ៉ៅដកដង្ហើមធំបែបព្រួយខ្លាំង ) តាំងពីឪម៉ែជីដូនជីតាអញរហូតមកដល់អញក្បាលកញ្ចាស់ ប៉ុណ្ណេះ អញមិនដែលឮកូនក្រមុំអ្នកឯណាដេកយំចង់បានប្តីមើលតែក្មេងទារស៊ីនំឥចឹងទេ ! ទើបតែមកប្រទះឯងមួយហ្នឹងហើយ ...ហ៊ឺ...!

-គេមានកូនក្រមុំបីបួននាក់គេមិនពិបាកចិត្ត ពុកនិងម៉ែមានកូន តែខ្ញុំមួយម៉្ងៃៗរអ៊ូរទាំថាពិបាក នេះមកពីពុកមិនស្រឡាញ់ខ្ញុំ មិនអីទេពុក អើយ ... បើពុកអស់ធមិមេត្តាលើខ្ញុំហើយ ខ្ញុំគង់តែទៅចងកសម្លាប់ទេ! ពុកឯងនៅរស់ម្នាក់ឯងចុះ !

នាងធឿននិយាយចប់ ក៏តាំងស្រែកយំក្ដែងៗ បោកក្បាលទៅលើខ្នើយឱប អណ្ដឺតអណ្ដក់ ធ្វើឱ្យគេឯងអាណោចអាធ័ម ។

មីងឡឹក ភ័យណាស់ខ្លាចកូនក្រមុំស្លាប់ ប្រឹងស្ទុះទៅចាប់កុំឱ្យបោកក្បាលនឹងខ្នើយឱប :

-ឈប់កូន ! ស្ដាប់ពាក្យម្ដាយសិនកុំបោកខ្លួនប្រាណកុំគិតផ្ដេសផ្ដាសទៅចងកសម្លាប់ខ្លួនណ៎ា! ...មនុស្សសម្លាប់ខ្លួនឯងចុះនរក ព្រះប្រោសមិនរួចទេ!

-កុំ ! កុំម៉ែ ...កុំឃាត់ខ្ញុំ (នាងធឿនប្រឹងបំរះ ) បណ្ដោយឱ្យខ្ញុំស្លាប់ទៅចុះ ដល់កប៉ុណ្ណេះហើយ មិនខ្ចីនៅរស់ឱ្យខ្មាសឆ្កែទេ ! អភ័ព្វ ណាស់ខ្ញុំលោកអើយ ! ក្នុងជាតិនេះ !!!

-គិតយ៉ាងម៉េចទៅពុកវាវឿងហ្នឹង !

មីងឡឹកប្រឹងស្រែកសួរយោបល់ប្ដី ភ្នែកបើកធំៗប៉ុនពងមាន់ ។

-កុំសួរអញ ...! អញលែងចេះគិតហើយ បើប្រុសទៅវាចង់បានប្រពន្ធ អញស្រួលចូលទៅស្ដីដណ្ដឹងឱ្យ ដល់មកប៉ះកូនស្រីយំទារ ចង់បានប្ដីអញមិនដឹងធ្វើយ៉ាងម៉េចទេ ! ឯងចេះទៅរកទិញប្ដីឯណា ឱ្យវាបាន ក៏រកចុះ ...

ពូញៀវឆ្លើយទៅប្រពន្ធធ្វើមុខស្មើ ។

នាងធឿនហាក់ដូចជាចេះអាណិតអាសូរឪពុកម្ដាយខ្លះ ក៏លែងរើបំរះអង្គុយស្រួលបួលដូចគេដូចឯង។ មីងឡឹកឃើញដូច្នោះ អរសែនអរ គាត់ ធូរខ្លួនដូចដកបន្លាស្អិតចេញពីទ្រូង ប្រញាប់និយាយលួងលោម ទៅបុត្រីត្រួយប្រមាត់ភ្លាម !

-ឈប់យំសោកបោកក្បាល ! ឈប់តាំងចិត្តចងក ណាពៅណា រឿងចង់បានប្ដីមិនអីទេចាំម៉ែជួយ តើសព្វថ្ងៃកូនជាប់ចិត្តស្រឡាញ់កម្លោះណា ប្រាប់ម៉ែឱ្យបានដឹងផងមើល៍ ?

នាងធឿន ឮសំដីម្ដាយត្រេកអរញញឹមបិទមាត់លែងជិតស្ទុះទៅអង្គុយទល់មុខឱនក្រួញក្រាញសំពះទាបបាទាមីងឡឹកបីដង ទើបហារមាត់ឡើងស្ដី :

-ចាំម៉ែ ! ខ្ញុំស្រឡាញ់លោកគ្រូសូត្រ ជួន វត្តយើងនុ៎ះអី !

-ស្លាប់អញម្ដងទៀតហើយ ! ( មីងឡឹកគក់ទ្រូង ) ស្រឡាញ់អ្នកណាមិនស្រឡាញ់ ទៅស្រឡាញ់លោកសង្ឃ ក្រែងឯងដឹងថាលោកគ្រូ សូត្រ ជួនជាលោកសង្ឃដែរហ្អី ?

-ចាំ ចឹខ្ញុំមិនដឹង ! តែឱ្យលោកសិកមក មើលលោកបងសន ម៉េចក៏គេចេះសិកមកការនឹងមីរ៉ែនកូនអុំគាំបាន !ចុះត្រង់លោកបង ជួន ម្ដេចក៏សិកមកការជាមួយខ្ញុំមិនបាន ?

-ហ៊ឺ ! មិនកើតទេការធឿនកុំនាំឱ្យម៉ែចុះនរកតាមអី អន្ទិតសន គេសិករួចហើយ បានគេមកដណ្ដឹងប្រពន្ធជាក្រោយ កូនឯងស្រឡាញ់ អ្នកណាផ្សេងទៀតទៅ កម្លោះភូមិយើងមិនខ្វះទេសំរាប់ទុកឱ្យឯងរើស ម៉ែសុំចិត្តតែលោកសង្ឃមួយចុះ ! ...

នាងធឿន អង្គុយស្ញៀមមួយសន្ទុះអង្គុយគិតពិចារណា លុះនឹកឃើញរឿងអ្វីមួយក៏ស្រាប់តែសើច ហះ ! ហះ ! ឡើង រញ្ជួយផ្ទះ :

-ហា ! ហា ! ហា !មិនអីទេម៉ែកុំព្រួយ! មិនបានលោកបងជូន បានអ្នកណាផ្សេងទៀតក៏ខ្ញុំព្រមដែរ ស្រេចតែលើម៉ែឪទុកដាក់តែសុំឱ្យ របស់កុំឱ្យយូរណ៎ា !

មីងឡឹកបែរទៅមើលមុខប្តីចង់ពិគ្រោះ ពូញ៉ៅដឹងទាន់ក៏ ប្រញាប់គ្រវីក្បាលរាដៃមកវិញ ឃើញដូច្នេះមីងឡឹកក៏អារកាត់ខ្លួនឯង និងនាងធឿនថា :

-អើមិនអីទេចាំគិតគូរឿងហ្នឹងឆាប់ៗឱ្យ ឥឡូវឯងដេកទៅណ៎ា! កុំយំកុំសោកទៀត ...

-ចាំម៉ែ !

នាងធឿនឆ្លើយប្រញាប់ ។

មីងឡឹកនឹងពូញ៉ៅ អស់កិច្ចការនិយាយទៀតហើយ គាត់ក៏នាំគ្នាក្រោកដើរចេញទៅ ។ នាងធឿនដើរតាមក្រោយម្តាយទៅបិទទ្វារបន្ទប់ រួចនាងក៏មកប្រោសខ្លួនដេកលើគ្រែ ស្រមើលស្រម៉ៃ ញញឹមញញែមញញាក់មុខញញាក់មាត់ម្នាក់ឯងដូចមនុស្សឆ្កួត ។

រាត្រីនេះ នាងធឿនដេកច្រៀងបទអណ្តើកស៊ីត្រកួនទាល់តែ យាមបីទើបដេកលក់ ។

-២-

## ស្នេហារន្ទះបាញ់

ឪម៉ែប្រើមកឱ្យឃ្វាលគោ ត្រូវខ្យល់ជំនោរដេកលក់លង់
ភ្ញាក់ឡើងជួបភ័ក្ត្រប្រុសឆោមយង់ ទាក់ទងព្រមប្រាណចូលព្រៃក្បា ។

ព្រះចន្ទពេញវង់រះភ្លឺច្បាស់ នាយព្រិលវិបល្លាសក្នុងចិន្តា
ស្រម័យបានថើបកែវកន្និដ្ឋា រន្ធះស្នេហាបាញ់ពកថ្ងាស ។

ថ្ងៃបណ្តើរកូនចោលពន្លឺព្រិចៗ ក្តៅស្មើរលាករលួយថ្លើមប្រមាត់ ស្លឹករុក្ខជាតិនានា ឡើងស្លោកស្វិតក្រៀមក្រញេងក្រញង់ដូចឃ្លង់កាច់ ។ មនុស្សសត្វនាំគ្នាចូលទៅជ្រកក្រោមម្លប់ឈើធំៗ សម្ងំពួនចាំពេលថ្ងៃ រសៀលនឹងអាលចេញទៅរកស៊ីប្រកបការងារតទៅទៀត។

នាងធឿនម្តាយប្រើមកឱ្យឃ្វាលគោ អង្គុយផ្អែកក្បាលនឹងដើមអំពិលស្វាបហិមៗទោរទន់ត្របកភ្នែក តាំងចិត្តថាដេកមួយស្រឡេតចាំ ថ្ងៃជ្រេរអន់ក្តៅបន្តិចសឹមដេញគោឱ្យទៅស៊ីស្មៅឯវាល ។ ខ្យល់បក់រំភើយៗ ផ្កាអំពិលជ្រុះពីទងធ្លាក់ ពេញក្បាលដូចគេបាចផ្កាស្លានាងធឿនដេកញញឹមស្រម័យកណ្តាលថ្ងៃត្រង់ ដល់ថ្ងៃរៀបការរបស់នាងមិនយូរប៉ុន្មានក៏លង់លក់លែងដឹងខ្លួនប្រាណក្បែរគល់អំពិលនោះទៅ ។

នៅឯគុម្ពោតព្រៃខាងមុខឯណោះ នាយព្រិលក្បាលទំពែក ដេកគងអន្ទាក់ខ្លា លើបង្កាបមែកព្រីងផ្អឹស្លឹកឫស្សូរគ្រលួចកណ្តាលអធ្វាស្ងាត់យូរៗ នាយឈប់ផ្លុំនឹកអផ្សុកក៏ច្រៀងលើកបទរាយទំនុកថា :

សកវាទីផ្កាឪឡឹក ក្រមុំខែកត្តិកចង់បានប្តី
ដេកយប់មមើឱបគល់ឫស្សី ភ្ញាក់ឡើងអត់អីស្រីអង្គុយយំ
សកវាទីផ្កាចេកទុំ អូនអើយឈប់យំឈប់ភិតភ័យ
បងក្បាលទំពែកដុះសក់ខ្លី រង់ចាំអូនស្រីរួមវាសនា
សកវាទីផ្កាក្រូចឆ្មារ បានពាក្យពីណាថាបងខ្មៅ

បើទុកជាខ្មៅក៏កូនខ្មែរ ចេះធ្វើស្រូវស្រែមានល្អង់អី ។
សកវាទឹផ្កាចំប៉ី សាសន៍ជាតិដទៃសតែសាច់
សឥតចេះដឹងស្អុយជាងអាចម៍ បងខ្មៅកខ្វាច់ខ្មៅមានជាតិ ។

ច្រៀងចប់នាយព្រឹលក៏ផ្លុំស្លឹកកំដរអារម្មណ៍តទៅទៀត ។

ល្ងាចត្រជាក់ទន់ទាបព្រះសូរិយា នាងធឿនផ្ងារខ្លួនភ្ញាក់ឡើងឮសូរសម្លេងនាយព្រឹលច្រៀងផ្លុំស្លឹក នឹកចម្លែកក្នុងចិត្តជាពន់ពេក។ អត់ទ្រាំពុំបានក៏ក្រោកដើរលបៗតាមរកម្ចាស់សម្លេងទិព្វ ដោយនឹកក្នុងចិត្តខ្លួនឯងថាៈ ឱ! អ្នកណាអើយ... ក៏ចេះច្រៀងចេះផ្លុំស្លឹកអ្វីក៏ពិរោះម្ល៉េះ! សម្លេងស្លឹកឮគ្រលួចដូចសម្លេងខ្លុយព្រះអង្គមុនី សម្លេងច្រៀងសោត ទៀតក៏ស្រួយស្រេះដូចសម្លេងសារិកាកែវវង តើរូបអ្នកស្រស់ភុំផាន ម្ដេចទៅអ្នកសម្ងំពួននៅកន្លែងណា អាណិតមេត្តាបញ្ចេញរូបរាងឱ្យ អូនឃើញផង ! ...

គិតបណ្ដើរដើរបណ្ដើរ ក៏ដល់ក្រោមដើមព្រីងកន្លែងដែលនាយ ព្រឹលដេកច្រៀង ។ នាងធឿនខំប្រឹងអើតមើលរកអ្នកច្រៀង តែដោយមកពីដើមព្រីងធំមានមែកសាខាស្លឹកក្រាស់ពេកក៏មើលមិនឃើញ ។ រីឯនាយព្រឹលនៅពីលើដើមព្រីង មើលមកក្រោមឃើញរូបនាងធឿនច្បាស់។ នាយយើងបានចិត្តរិតតែខំដំអូញសំនៀងទិព្វឱ្យកាន់តែពិរោះ ជាងដើម នាងធឿនអត់ទ្រាំលែងបានក៏ផ្ទុះសម្លេងថា :

-យី ! អ្នកណាក៏ចេះផ្លុំខ្លុយចេះច្រៀងអ្វីក៏ពិរោះម្ល៉េះ ! អ្នកនៅឯណាទៅ ម្ដេចក៏ខ្ញុំរកមើលមិនឃើញ ឬមួយក៏ជាសម្លេងខ្មោចព្រាយ បិសាចមកបន្លាចលងខ្ញុំទេដឹង ?

និយាយរួច នាងធឿនក៏ឈានជើងដើរចេញពីក្រោមដើមព្រីង ដោយអស់ក្ដីសង្ឃឹមនឹងបានជួបម្ចាស់សម្លេងទិព្វ ។ នាយព្រីលឃើញ ដូច្នោះក៏លោតព្រួសមកដី បណ្ដាលឱ្យស្រីភ្ញាក់ស្រែកយ៉ៃ !

-ម៉ែអើយជួយកូនផង ! ខ្មោចលងហើយ !

-ឈប់ស្រែកឈប់ភ័យទៅ បងមិនមែនជាខ្មោចព្រាយបិសាចទេ បងគឺជាអ្នកផ្លុំស្លឹកដែលអូនតាមរកមើលអំមិុញទេតើ

នាងធឿន ងាកមើលឃើញជាក់ជាមនុស្សក៏អន់ភ័យ ត្រឡប់ធ្វើកិច្ចកលមាយាដកខ្លី និយាយវៀចមាត់វៀចកថា :

-ខ្ញុំមិនមែនតាមរកមើលអ្នកឯងទេ ! ខ្ញុំដើរមករកមើលបេះផ្លែព្រីង ទេតើ !

នាយព្រីល សើចនឹកអស់សំណើចនឹងសំនួនដោះសារនាង ធឿន :

-ឱ ! ព្រះម្ចាស់ថ្លៃអើយ... តាំងពីករទឹកករដីមកដែលមានឬ ដើមព្រីងមានផ្លែខែកត្ដិក ហា ! ហា ! ហា !

នាងធឿនទាល់ប្រាជ្ញឈរស្ងៀម កម្លោះព្រីលបានឱកាសក៏បន្ថែមសំនួនវោហារ :

-កុំខ្មាសអៀនអី ! ស្រុកយើងស៊ីវិល័យ នរណាគេដែលប្រកាន់ យើងអ្នកស្រុកភូមិរបងជាមួយគួរណាស់តែរាប់រកគ្នា អូនភ្លេចមុខបងហើយឬកាល

ថ្ងៃការអាអន្ទិតសននាងរនែនុំះអី បងទៅជួយកំដរខាង កូនកម្លោះហើយអូន ខាងណោះ ទៅជួយកំដរខាងកូនក្រមុំមែនទេ ?

-ចាំ ! ត្រូវហើយបង ... តើបងឈ្មោះអ្វីទៅ ?

-ឈ្មោះបងឬ ? បងឈ្មោះព្រឹល ! ពីដើមបួសលោកភិក្ខុ នៅកុដិជាមួយអាអន្ទិតសន ! តើអូនឈ្មោះអ្វីដែរ ?

-ចាំ ខ្ញុំ ... ខ្ញុំ... ឈ្មោះធឿន !

-អូ ! អូ ! ឈ្មោះធឿន ( នាយព្រឹលផ្ទួនពាក្យ ) ធឿនព្រឹល ! ព្រឹលធឿន ! យី ! ឈ្មោះយើងទាំងពីរនាក់ជួនគ្នាទេតើ !

-មិនដឹងជាជួនស្អីទេ ! មួយធឿនមួយព្រឹលខុសច្បាប់គ្នាឆ្ងាយ ណាស់ !

នាងធឿនប្រកែក ។

នាយព្រឹលវែធអណ្តាតភ្លែម១ ញាក់ចិញ្ចើមព្រើត១ដាក់នាង ធឿន ។ នឹកដល់គណគ្រូបាធ្យាយនីសណ្តំសែកមន្តស្នេហ៍សារិកាលិន ថោង តាមរបៀបវិធីដែលធ្លាប់សូត្ររៀន ។ អូមអាមក្នុងចិត្តមួយសន្ទុះ ក៏និយាយទៅកាន់ នាងធឿនថា :

-អូនឯងនៅល្ងង់ណាស់ក្នុងការសិក្សា ប្រែឈ្មោះ "ធឿន" គឺ ប្រែក្លាយចេញមកពីពាក្យ "ធនធាន" ប្រែចេញមកទៀតបានសេចក្តីថា របស់ទ្រព្យផ្សេង១ដែលគង់នៅមិនទៅណា ចំណែកបង "ព្រឹល"ក្លាយ ចេញមកពីពាក្យ "ព្រហ្ម" ប្រែចេញមកគឺសេចក្តីចំរើន សេចក្តីរីករាយក្នុងចិត្ត, សេចក្តីប្រសើរ ឬទេវតាដែលកើតនៅព្រហ្មលោកដោយ អំណាចផលនៃឈានចិត្ត គឺព្រះព្រហ្ម នុំះអី !ឃើញទេ ! ឈ្មោះយើង ទាំងពីរនាក់ដល់មកបកស្រាយជាពាក្យបាលី

ល្អវិសេសណាស់ ! ក្រោមមេឃលើដីមិនងាយរកក្រមុំកម្លោះឯណា ឈ្មោះជួនប្រែបានសេចក្ដីល្អ ដូចយើងទេ ...!

នាងធឿន ពេញចិត្តនឹងនាយព្រឹលមានប្រាជ្ញាវៃវិញញឹមខ្ចឹប ប៉ោងថ្ពាល់ស្ទើរប្រេះ ។ ក្រមុំបរមាណូនឹកសរសើរវាសនាខ្លួនឯងថា ប្រហែលជាគូ ព្រេងពីបុព្វេហើយ បានជាទេវតាបណ្ដាលឱ្យមកជួបគ្នា កណ្ដាលព្រៃស្វាត់ សមនឹងបំណងនាងប៉ងចង់បានប្ដីស្រាប់ដូច្នេះ ។

កម្លោះព្រឹល ដឹងថានាងធឿនបេត្តីលើខ្លួនខ្លះៗហើយក៏ សម្លឹងមើលទៅមុខនាងមិនព្រិចភ្នែក ។ ភ្លើងស្នេហ៍ឆាបឆេះពេញផ្ទាំងទ្រូង ក្រមុំកម្លោះ ភ្នែកនឹងភ្នែកក្រឡេកមើលចំគ្នាចង់ជ្រុះប្រស្រី។ នាយព្រឹល ព្រឺព្រួចឡើង សម្បុរគីង្គក់, ទឹកមាត់ខះ, ភ្នែកក្រហមឆ្លែដូចភ្នែកអែអូដ្ឋ។ រីឯនាងធឿនវិញ ចំហាយក្ដៅស្ទុះកញ្ជ្រោលចេញភាយៗគ្រប់សរសៃសរ សូងរោមតូចធំបបេរមាត់ខើច, ញ័រក្បាលជង្គង់, ក្នុងទ្រូងលាន់ឌឹបៗ ដូចគេទូងស្គរ, ថ្ពាល់ទាំងគូរ ឡើងក្រហមចាស់ ដូចផ្លែបាស់ទុំ ។

ឈរស្ងៀមស្ងាត់មួយស្របក់ធំ ទើបឮនាយព្រឹលផ្ដើមនិយាយថា :

-អត់ទោស ! បងចង់នាំអូនទៅនិយាយគ្នាលេងនៅគុម្ពោតព្រៃ ខាងមុខបានទេ ?

-ចាំ៎ មានទាស់អ្វី !

នាងធឿនឆ្លើយប្រញាប់ដោយមិនចាំបាច់គិត

-បើអីចឹងទៅអូន ! ចាំល្ងាចត្រជាក់មែនទែន បងជួយគៀងគោ ឱ្យ ។

-ចាំ៎ះ ! ...

ផុតវាចា នាងធឿនក៏ដើរតាមក្រោយនាយព្រឹលសំដៅទៅ គុម្ពោតព្រៃខាងមុខ ។

..................................................................

ព្រលប់ហើយ ...

កសិករប្រុសស្រី នាំគ្នាឈប់សំរាកពីកិច្ចការស្រែចំការដើរកាត់ តាមភ្លឺស្រែជាជួរ ហួរហែតំរង់ឆ្ពោះទៅផ្ទះដោយដំណើរខ្ជិឃ្នាត។ ក្មេងៗ ឃ្វាលគោក្របីមាត់ស្រែកកោកកាកដេញសត្វពាហនៈដែលរត់ឆ្វេឆ្វាតាមជាន់ញីឱ្យប្រមូលផ្តុំ ។ ម្នាក់ៗខំប្រឹងដេញសត្វស្រូតដំណើរទៅបញ្ចូល ក្រោលរៀងៗខ្លួន ដើម្បីគេចឱ្យផុតពីស្រមោលសន្ធិយាដែលកំពុងគ្របដណ្តប់ ។

នាយព្រឹល ក្រោយពីអង្គុយសំណេះសំណាលពាក្យពេចន៍ ស្នេហាជាមួយនាងធឿនអស់ចិត្តអស់ចង់ហើយ ក៏នាំគ្នាក្រោកដើរ ចេញពីគុម្ពោតព្រៃមកវិញ

ចៅមាណពក្បាលទំពែក ជួយគៀងគោជូនដំណើរសង្សារថ្មី មកដល់ចុងភូមិ ទើបអ្នកបំបែកផ្លូវត្រឡប់ទៅផ្ទះ :

-អូនធឿន! បងជូនអូនត្រឹមហ្នឹងចុះអូនក៏ជិតដល់ផ្ទះហើយយប់ នេះអូនគេងយល់សប្តិល្អណ៎ា ស្អែកចាំយើងជួបគ្នានៅកន្លែងដដែល ទៀត សួស្តី ...

-ចា៎ បង ! ... សូមបងអញ្ជើញទៅឱ្យសុខសប្បាយ ។

នាយព្រឹល ងាកមុខមកញញឹមដាក់នាងធឿនម្តងទៀតជា សញ្ញាលារួចហើយអ្នកក៏ដើររលះរលាំងហួច ក្ងេវ ! ក្ងេវ ! កាត់តាម ផ្លូវលំ រហូតបាំងបាត់ស្រមោលនឹងគុម្ពសង្កែធំៗខាងមុខ ។

នាងធឿន ឈរតាមមើលសង្សារទាល់តែលែងឃើញ នាងក៏ឡើងជិះមេគោត្រឡប់ទៅផ្ទះវិញដែរ ។ រាត្រីនេះជារាត្រីសែនសុខ មនោរម្យបំផុតក្នុងជីវិតនាងធឿន ។ ស្រស់ស្រីដេកមិនលក់ បក់មិន រហើយ ក្នុងខ្លួនចេះតែរសាប់រសល់, រមាស់, ស្ទៀប, រកស្ថានមិនត្រូវទីបំផុត នាងក៏ដើរទៅបើកបង្អួច សម្លឹងមើលផ្ទៃមេឃានាថ្ងៃ១៤កើត ព្រះចន្ទពេញវង់រះមូលក្រឡង់ដូចប្រាក់កាក់ ។ ខ្យល់ជំនោរខែកត្តិក បោកប៉ះអង្គប្រាណនារីឱ្យត្រជាក់ដល់ខួរឆ្អឹង ។ ខំសម្លឹងមើលព្រះចន្ទ យូរៗក៏ ហាក់ដូចជាមុខអ្នកកម្លោះព្រឹលកំពុងញញឹមមករកនាងទេសភាពពេលរាត្រីអ្វីក៏សែនស្រស់ម្ល៉េះ រស្មីព្រះចន្ទចោលពន្លឺស្រទន់ ទៅលើមែករុក្ខជាតិនានា បណ្ដាលឱ្យករកើតទៅជាពន្លឺភ្លឺផ្លេក ! ផ្លេក! ឱ ! ពេលថ្មើរនេះ បើបាននាយព្រឹលមកនែបនិត្យជិតអង្គប្រាណ តើនាងធឿនសប្បាយដល់ កំរិតណាទៅអេះ ?

ស្រីក្រមុំឈរបណ្ដែតអារម្មណ៍នឹងព្រះចន្ទ ទាល់តែភ្លេចខ្លួន នាងកំពុងស្រម័យថា នាងនៅជិតនាយព្រឹល ពេលមួយនាងក៏និយាយចេញ មកម្នាក់ឯងរបៀបមនុស្សរវើរវាយខូចសតិថា :

-ឱ ! រស្មីព្រះចន្ទ...ឱ ! បងព្រឹលបណ្ដូលជីវិតអូនអើយ..! រង្វង់ភក្ត្រព្រះចន្ទនិងមុខបង ម្ដេចក៏ល្អដូចគ្នាបេះបិតម្ល៉េះ ...! ជាតិមុនបងប្រហែលជាព្រះចន្ទទេដឹង ? មើលចុះលោកអើយ...បងព្រឹលចេះញញឹមរកអូន ម្ដេចក៏មិនសារសងរកអូនផង ពេលនេះអូនរងារណាស់..!

បើទុកជាពាក់អាវក្រាស់ៗ ធ្វើអំពីស្បែកក្របី ដណ្ដប់ភួយបួនដប់ ជាន់ក៏មិនបាត់រងារដែរ បើបានបងមកឱបរិតក្បៀកកើយរួមខ្នើយជាមួយអូយ !...

ម្លេះសមអូនព្រីព្រួចគ្រប់រោមា កក់ក្ដៅតាំងពីក្រៅរហូត ដល់បេះដូង ... យី ! មានបងព្រីលឯណា ខ្ញុំនិយាយម្នាក់ឯងទេតើ ហា ! ហា ! ហា ! ស្នេហាវាចង់នាំឱ្យឯងឆ្កួតមែនទែនហើយតើ !

នាងធឿនគ្រវីក្បាល នឹកអស់សំណើចខ្លួនឯងទាញទ្វារបង្អួច បិទដូចដើម ហើយក៏ដើរមកប្រាសខ្លួនដេកលើគ្រែវិញ ។

នៅពេលជាមួយគ្នានេះ យើងបែរទៅមើលផ្ទះនាយព្រីលម្ដង។ នាយព្រីលដេកមិនលក់បក់មិនរហើយកើយមិនស្រណុកដូចជានាង ធឿនដែរ ។ ក្លិនប្រហើរនៃថ្ពាល់នាងធឿនជិតជាប់ច្រមុះប្រុសកម្លោះ មិនទាន់បាត់ពាក្យពេចន៍ថ្លាថ្លៃងក្ដីស្នេហា កាលពីថ្ងៃនៅព្នុក្នុងសោតា ជាប់ជានិច្ច។ រង្វង់មុខមូលក្រឡង់សម្បុរខ្មៅស្រអែមស្រស់តាមធម្មជាតិ ធ្វើឱ្យកម្លោះព្រីលស្ទើរចង់ឆ្កួតចិត្តម្ដងៗ ។ ក្រមុំនៅក្នុងភូមិ នាងធឿន មានរូបសម្ផស្សស្អាតដាច់គេឯង នាងគឺជាផ្កាកុលាបប្រចាំភូមិ ដូច្នេះគឺ មិនមែនមានតែនាយព្រីលម្នាក់ទេដែលស្រឡាញ់នាង ប្រុសកម្លោះជា ច្រើនចង់ធ្វើវាសនាលើនាង តែអ្នកទាំងអស់នោះនៅខ្លាច នៅញញើត ញញើមមិនហ៊ានហើបមាត់និយាយ គឺសុទ្ធតែអ្នកល្ងង់ខ្លៅក្នុងរឿងស្នេហាមិនពូកែឱត ! ហេតុនេះគួរចាត់ទុកនាយព្រីល ឬអន្ទិតព្រីលជាឆ្នើម កម្លោះផុតលេខ ដែលស្រវាយកបុប្ផាព្រៃភ្នំមកថ្នាក់ថ្នមបានមុនគេ ។

ធាតុអាកាសពេលយប់ជ្រៅ កាន់តែត្រជាក់ខ្លាំងឡើងៗ ។ ភ្លើងស្នេហ៍គ្រាដំបូងនៃជីវិតកម្លោះ ធ្វើឱ្យនាយព្រីលវិលខួរក្បាល ដួងចិត្ត វិបល្លាស ភ្នែករវេរវៃពេគន់មើលទៅកន្លែងណា ឃើញតែមុខនាងធឿន ញញឹមប៉ប្រែមករក។ ទ្រាំមើលតទៅទៀតលែងកើត ចៅមាណពក៏បិទ ភ្នែកយកដៃគ្របពីលើសម្ងំ

ដេកឱ្យលក់គិតថាព្រឹកស្អែកនឹងយករឿងនេះ ទៅប្រាប់ឪពុកម្ដាយឱ្យបានដឹង តែមិនបានប៉ុន្មាននាទីនាយក៏ដកដៃចេញ បើកភ្នែកក្រលួងបែរទៅគៀនជញ្ជាំង ប្រុងទាញខ្មើយឱបមកឱបឱ្យកក់ ក្ដៅអន់រងារស្រាប់តែបាត់ឯខ្នើយឱបត្រឡប់ជាឃើញនាងធឿនសង្សារ កំពូលបេះដូងដេកស្រាតនៅក្បែរខ្លួនជិតបង្កើយ ។

អុញ្ញន៎ ! ដល់ហើយតើអន្ទិតព្រឹល ! ស្នេហាចូលភ្នែក មើលឃើញខ្នើយឱបទៅជានាងធឿន ។ នាយយើងញីភ្នែកខ្លួនឯងបីបួនដង ក្រែងមិនមែន តែមេរោគឆ្កួតកាមរាគៈចូលក្នុងខ្លួនស៊ប់ទៅហើយ ។ ក៏នៅតែមើលឃើញជានាងធឿនដដែល ។ បុរសឈ្លក់ទឹកយ៉ៅហៅ សម្លឹងមើលខ្នើយឱបស្រក់ទឹកមាត់ច្រោក គេឃើញជានាងធឿនដេក ស្រាតកំពុងញញឹមមករកគេសាច់ភ្លៅនាងម្ខាង១ឡើងទ្រលុក១ដូចភ្លៅ គោ សុដន់ទាំងគូក្បុំស្រួចដូចផ្កាព្រលិតឈ្លក់ទឹក ។ កាន់តែមើលយូរ ទៅកាន់តែ ស្រស់ ! កាន់តែសម្លឹងក៏កាន់តែព្រឺព្រួច, ឃ្លាន, ចង់, តាម ចំណង់កម្លោះឈាមរាវ ។

នាយព្រឹល អង្គុយហៀរទឹកមាត់កខ្លាក់ដូចឆ្កែឆ្កួត អ្នកសម្លឹងមើលតាំងពីចុងជើង ទៅដល់ជង្គង់, ភ្លៅ, ក្រលៀន, ក្បែរ ក្រលៀន, ផ្ចិត, ពោះ, ទ្រូង, ដោះ, កញ្ចឹងក, មុខ, សក់,ពីលើចុះក្រោមពីក្រោម ទៅលើ បីបួនសារ ។ ម្ដងនេះម្ចាស់វិស័យនឹងទ្រាំបាន នាយយើងក៏ស្ទុះ ភ្លែតឱបពោបពីលើខ្នើយឱបដែលគេសន្មតថាជារូបនាងធឿន ។ ភ្លើង ស្នេហ៍កំពុង ឆាបឆេះពេញបន្ទុកនាយព្រឹលឱនថើប, ជញ្ជក់, ច្របាច់ ខ្នើយឱបឮសូរសឹតសត ! សឹតសត ! ពព្រូសពប្រាសពេញបន្ទប់ រីឯ មាត់ចេះតែ និយាយប៉ប៉ាច់ប៉ប៉ោចមិនដាច់សូរ :

-ធឿនអូនអើយ ! បងស្រួលណាស់ ...! អូនមកនេះ មកចិត្តឯងឬមួយទេវតាលោកនាំអូនមកយី !អូនចេះញញឹមរកបងតែមិនព្រមឆ្លើយឆ្លងមកបងសោះ ...អូ ! មែនហើយប្រហែលជាអូនអៀន .... ឈប់អៀនខ្មាស់ទៅអូន ទោះជាយ៉ាងណាអូន និងបងក៏ជាប្ដីប្រពន្ធគ្នា ហួសទៅហើយ ! ហ៊ឺ ! កុំភ័យពីរឿងអនាគតអាណាលើសអីណ៎ា សេចក្ដីសុខ, សប្បាយព្រឺព្រួច, មានប៉ុន្មាននៅក្នុងលោកបងសូមឡាយ ឡុងទិញយកមកជូនអូនទាំងអស់ ! ក្នុងលោក... ពិភពស្នេហា ... អាណាចក្រសុភមង្គលត្រូវបានមកលើរូបយើងពីរនាក់គត់ ហា ! ហា ! ហា !

និយាយរួច នាយព្រឹលក៏បោលសំរុកបុកខ្នើយឱបយកជ័យជំនះនៅគ្រាបញ្ចប់ បណ្ដាលឱ្យជ្រុលហួសខ្លួនអណ្ដែតផុតពីលើគ្រែ ក្បាលទៅបុកនឹងដងនង្គ័លដែលនៅក្បែរនោះឮសូរប៉ុង ! បែកអំពិល អំពែកភ្លឺក្នុងភ្នែកព្រាត ។ នាយព្រឹលភ្ញាក់ដឹងខ្លួននឹកស្មានថារន្ទះបាញ់ចំ កណ្ដាលក្បាលក៏ស្រែកយ៉ូយ ! លាន់រំពងពេញផ្ទះកណ្ដាលអាធ្រាត្រស្ងាត់ ។

ពូព្រើលមីងព្រាបភ្ញាក់នឹងសម្លេងកូន ក៏នាំគ្នារត់ត្រសងមកកាន់បន្ទប់នាយព្រឹល ។ ឃើញកូនដេកប្រកាច់ថ្ងូររហ៊ឹម ពកថ្ងាសប៉ុនផ្លែចន្ទ ភ័យណាស់ប្រញាប់ម្នីម្នាលើកដាក់ឱ្យដេកលើគ្រែ។ មីងព្រាបក៏សួរថា:

-វាយ៉ាងម៉េចកូនព្រឹល ! ប្រាប់ម៉ែមកមើលឯងកើតអី ?

នាយព្រឹលបាត់ឆ្កួត នឹកដល់ភាពដែលកន្លងមក ក៏ខ្មាស់ ខ្លួនឯងដឹងជាក់ជាខ្នើយឱបមិនមែននាងធឿន ហើយមិនមែនរន្ទះបាញ់ទេ គឺក្បាលទៅបុកនឹង

ដងនង្គ័ល ។ នាយយើងធ្វើមុខស្មើ និយាយលាងខ្លួនទ្រង់អឹមអៀនទៅកាន់ម្ដាយ :

-ម៉ែកុំព្រួយខ្ញុំអត់កើតអីទេ ...! អំមិញខ្ញុំដេកយល់សប្ដិមមើមមាយថារន្ទះបាញ់ខ្ញុំណាម៉ែ !

មីងព្រាបសំដែងអាការៈភ្ញាក់នឹងសុបិនចំឡែករបស់កូន បន្ទាប់មកគាត់ក៏និយាយលួងលោមនាយព្រើលថា :

-យល់សប្ដិរន្ទះបាញ់ល្អទេកូន ឯងពីថ្ងៃនេះទៅផុតគ្រោះថ្នាក់ ហើយ :

មីងព្រាបខ្ទេះប្រេងកូឡាមកលាបថ្ងាសពក ហើយគាត់ក៏បន្តសំដីទៀតៈ

-សម្ងំដេកទៅណា បើស្រួលមិនស្រួលយ៉ាងណាចាំដាស់ម៉ែឮ ទេ ?

-បាទ !

ពូព្រើលមីងព្រាបដើរចេញទៅបាត់ហើយ នាយព្រើលដេកអស់ ចិត្តអស់សំណើចខ្លួនឯង គេដឹងខ្លួនថាអំបាញ់មិញនេះឆ្កួតពិតប្រាកដ ។

% %

%

-៣-

ស្នេហាមានក្បួន

កើតទុក្ខមុខព្រួយព្រោះរឿងស្នេហ៍ ជួបឪនឹងម៉ែឈ្លោះប្រកែក

រកវាយទាត់ធាក់រឿងកន្ទុយលេខ ព្រោះស្អែកខ្ទះលុយបង់តុងទីន។

លុះគាត់យល់យមព្រមរៀបការ លង់រឿងស្នេហាខ្លួនមិនប៉ិន
ស្អាត់សួរពួកម៉ាកឱ្យច្បាស់សិន ដ្បិតអ៊ីកន្ទុយក្បិនស្នេហ៍មានក្បួន។

ព្រឹកស្អែកឡើង នាយព្រឹលនិងនាងធឿនក៏មកជួបគ្នានៅកន្លែងដដែលទៀត ។ នាយយើងខំសម្លឹងពិនិត្យពិច័យមើលរាងរៅនាងធឿន ហើយក៏នឹកគិតទៅដល់ភាពដ៏អស្ចារ្យកាលពីយប់មិុញ ។ រីឯនាងធឿនកាលបើត្រូវគេសម្លក់សម្លឹងមើលផ្ចិតផ្ចង់ហួសការគួរ ក៏រឹងខ្លួនស្ទូក តែមកឃើញនាយព្រឹលពកថ្ងាស នាងក៏ធ្វើជាសួរបន្លប់អៀនថា :

-បងឯងកើតអីបានជាពកថ្ងាស ?

-ថ្ងាសបងឬ ? (នាយព្រឹលយកដៃអង្អែលថ្ងាស ) រឿងថ្ងាសពកនេះវាមានដើមទងវែងឆ្ងាយណាស់អូន កាលពីយប់មិុញបងនឹកអូនខ្លាំងពេក ទៅជាមមើមមាយភ្នែកស្រស់ថាអូនមករកបង បងស្ទុះទៅទទួលអូនជ្រុលហួសទៅបុកក្បាលនឹងដងនង្គ័លឃើញទេ! ចិត្តបង ស្នេហាទៅលើរូបអូនដល់ម្លឹងណ៎ា

ហា ! ហា ! ហា ! (នាងធឿនសើចសប្បាយចិត្តបានឮសំដី នាយព្រឹលថាស្រឡាញ់នាងខ្លាំងទាល់តែពកថ្ងាស ) យប់មិុញក៏អូននឹក មកបងព្រឹលឯងដែរ អូនបន់តែឆាប់ព្រឹកនឹងអាលមកសួរបងតើមាននឹកអូន ដូចអូននឹកបងទេ?

-យើងជាគូព្រេងនឹងគ្នាពីជាតិមុនហើយណាអូន បានជាទេវតា លោកមកបញ្ចូលចិត្តយើងទាំងពីរ ឱ្យចេះតែនឹករកគ្នាដូច្នេះ ។

ថាហើយនាយព្រឹល ក៏ទាញខ្លួនស្រស់ស្រីមកឱបផ្ទប់នឹងផ្ទាំង ទ្រូងឱនថើបថ្ពាល់ម្ខាង១ ប្អូនដប់ខ្សឹតយ៉ាងក្រហល់ក្រហាយ ។ នាង ធឿនលើកដៃទាំងពីរទៅឱបប្រុសស្នេហ៍ ភ្នែកនាងបើកព្រឹម១ ដូច ចង្កៀងអស់ប្រេង ។

អស់រយៈពេលមួយសន្ទុះធំ ទើបអ្នកទាំងពីរលែងប្រកៀកប្រឱបបែរមកអង្គុយស្រួលបួលដូចធម្មតាឡើងវិញ ។

-អូនធឿនអើយ ...!

-ចាំះ បងព្រឹល !

បងគិតថា ឱ្យឪពុកម្ដាយបងចូលទៅស្ដីដណ្ដឹងអូននៅពេលឆាប់ៗខាងមុខនេះ តើអូនយល់ដូចម្ដេច ... ?

-ចាំ ប្រសើរណាស់បង ! បងកុំកុហក់អូនណ៎ា... ប្រុសៗឥឡូវ អូនមិនសូវទុកចិត្តទេ ...

នាងធឿននិយាយហើយក៏ដកដង្ហើមធំ ធ្វើមុខក្រៀមផ្អេះ ។ នាយព្រឹលយល់ចិត្ត យកដៃទៅច្បូតសក់សង្សារស្រាលៗ ដោយក្ដីស្រឡាញ់ :

-បងមិនកុហក់អូនទេ ! ... បើអូនមិនជឿ ... ឱ្យបងស្បថដល់ណាក៏បងហ៊ានដែរ ...!

-បងឯងស្បថបន្តិចទៅមើល៍ ...!

-អុំ ! មានជាការស្អី ! (នាយព្រឹលលើកដៃសច្ចា) ខ្ញុំបាទមាន នាមប្រែត ព្រឹល ជាកូននាយព្រើល នាងព្រាប សូមលើកករប្រណម្យ ចំពោះវត្ថុសក្ដិសិទ្ធដែលស្ថិតនៅឋានសួគ៌, ឋានកណ្ដាល ឋាននរក ទាំងបីឋានសូមជួយធ្វើជាកសិណសាក្សីនៃខ្ញុំ ថាខ្ញុំនឹងស្រឡាញ់នាង ធឿនតែម្នាក់គត់ក្នុងលោក បើកាលណាហើយខ្ញុំបាទគេចកែភ្លេចសច្ចៈ វាចានេះ សូមឱ្យខ្ញុំស្លាប់តែហោង ចុះទឹកឱ្យស្លាប់នឹងកំពតច្រើប ! ដើរ ក្នុងព្រៃឱ្យស្លាប់នឹងឪម៉ាល់ទិច ! បើធ្វើទាហានឱ្យស្លាប់តែនឹងចុះរាកកុំ ឱ្យទៅច្បាំងកើត ! បើ ...

-ប៉ុណ្ណឹងបានហើយបងព្រឹល ! អូនជឿចិត្តហើយ ...

នាងធឿនយកដៃខ្ទប់មាត់នាយព្រឹលដោយឃើញនាយយើង ប្រុងបន្តសំបថថែមទៀត :

-អំបាញ់មិញ ! អូនចង់បញ្ជាក់បេះដូងបងតើស្មោះស្ម័គ្រលើអូន មែនឬក៏មិនមែន ឥឡូវអូនយល់ច្បាស់ហើយថាបងប្រាកដជាស្រឡាញ់ អូនមែន ...!

-ចិត្តបងឥចឹងណាអូន ! តែថាស្រឡាញ់ហើយឱ្យស្បថដល់ ណាក៏ហ៊ានដែរ ...!

នាយព្រឹលក្រោកឈរពត់ខ្លួន ងើយមើលថ្ងៃបន្តិចក៏បន្តសំដី :

-ថ្ងៃជិតត្រង់ហើយ ! អូនទៅរកមើលគៀងគោចូលម្លប់ចុះ បងលាអូនសិន ចាំថ្ងៃស្អែកយើងជួបគ្នាម្តងទៀត ។

វាចាចប់ នាយព្រឹលក៏ដើរចេញពីគុម្ពោតព្រៃ ដំរង់ទៅផ្ទះ ។ ចំណែកនាងធឿនក៏រវាសរវៃទៅគៀងគោចូលម្លប់ ។

មកដល់ផ្ទះនាយព្រឹលតាំងចិត្តចូលទៅជំរាបឪពុកម្តាយរឿងដែលខ្លួនគួចជំពាក់ចិត្តទៅលើនាងធឿន តែក៏ត្រូវអាក់ខានទៅវិញដោយពេលនេះពូព្រើលមីងព្រាបកំពុងឈ្លោះប្រកែកគ្នាពីរឿងបង់តុងទីន

-នែវើយមីកាព្រាប ! (ពូព្រើលស្រែកជេរទៅប្រពន្ធ) ហាងឱ្យអញបង់តុងទីនយ៉ាងម៉េចកើត បើអញមិនបានលេង ! មិនបានដេញ ! ស្រាប់តែដល់ពេលបង់ មកបន្ទុកបណ្តាក់លើអញឥចឹងមិនកើតទេ ។

-សំដីឱ្យល្មមៗលោកបងព្រើល ! កុំហារឡើងហៅអញហង ដាច់សាច់ប្រយ័ត្នអញហៅអាវិញណ៎ា ! លុយកាក់ចាយវាយទាំងអស់ គ្នា ! នៅផ្ទះជា

មួយគ្នា ! ស៊ីបាយទឹកជាមួយគ្នា ! ដល់តែពេលសង វា ត្រូវតែជួយសងគ្នាត ចឹងហើយ ! បើឯងមិនមែនប្ដីអញ ! មិនយក ...អញ ! អញក៏មិនខ្ចីឱ្យជួយរក សងដែរ !

-អើ ! អាការប្ដីប្រពន្ធត្រូវតែជួយឈឺឆ្អាលគ្នាតចឹងហើយ តែនេះ ហងគិតមើល ! ប្រាក់លក់គោបីនឹមពីខែមុនជាងពីរម៉ឺនអស់ !ស្រូវជាងពីររយ ថាំងក្នុងជង្រុករលីង ! តុងទីនបួនប្រាំក្បាលសុទ្ធតែងាប់! តើអញមានបានចាយ ឯណាមួយកាក់? ម៉ែ្ង៧ វរល់តែជិះឡានទៅវត្តនេះវត្ត នោះសុំចំណោទលោក មកចាក់កន្ទុយលេខបន្ទិចថាឆ្នោតជាតិ!បន្ទិចថា ឆ្នោតយួន ! បន្ទិចថាឆ្នោត សៀម ! មួយខែ៧ វរល់តែជញ្ជូនប្រាក់ទៅ ឱ្យអាសេងលីមេកន្ទុយលេខចាយ អញវាមិនដែលឃើញត្រូវម្ដងណាសោះ ! កាលអាលើកឆ្នោតសៀមចេញ លេខ៨៣ តើអស់ប៉ុន្មានពាន់ មាននឹកឃើញទេ ?

-អ្នកណាចង់ឱ្យខុស ! អ្នកលេងល្បែងតែងតែចង់ឈ្នះ បើវាត្រូវមួយ ចានមកលុយហ្នឹងវាទៅឯណាវាមិនស៊ីចាយសប្បាយទាំងអស់គ្នា ។

មីងព្រាបនៅតែមិនព្រមចុះញ៉មប្ដី ។

ពូព្រើលគ្រវីក្បាល បែរទៅស្ដោះទឹកមាត់ប្រហែលមួយពែងនំ អាកោ :

-អញមិនចង់ចាយទេអាប្រាក់ក្ដៅក្រហាយ ! អាល្បែងដែល រាជការ គេហាមនោះ ហងមានឮសម្ដេចឪព្រះអង្គលោកមានព្រះរាជ ឱង្ការតាមវិទ្យុ ជាតិទេ លោកហាមផ្ដាច់ទាំងរាជការទាំងស៊ីវិល ទាំង រាស្ត្រតូចតាច គ្រប់និគម ជនបទមិនឱ្យលេងបៀប៉ោជល់មាន់កន្ទុយលេខ ។ល។ ទាំងនេះដោយព្រះអង្គ

ទ្រង់ឆ្វេងយល់ថា វានាំឱ្យជាតិលិចលង់, ឱ្យរាស្ត្រក្រីក្ររហេមរហាមខូចចិត្ត ប្រកបរបររកស៊ីមិនកើត ! ចំពោះអ្នករាជការវិញមិនបាច់លេងទេ គ្រាន់តែស៊ីគ្រលំជាមួយអ្នកស្រុកឱ្យតែរាជការក្រុមពិសេស (Equipe Samdech Ov) ដឹង មុខជាត្រូវផ្លាស់ចេញ២៤ម៉ោង ពីមុខដំណែង រកតែរត់ទៅលាប្រពន្ធចុងក៏មិនទាន់ផង ដឹងហើយឮហើយម៉េចក៏នៅតែចង់លេងទៀតចង់ជាប់គុកឬមីកាព្រាប បើថាចង់ជាប់អញនឹងទៅប្ដឹង រាជការឱ្យមកអូសក្បាលហងបញ្ចូលគុកឥឡូវហ្នឹង !

ម្ដងនេះ ព្រោយកន្ទុយលេខហាក់ដូចជាដកឃ្លាចេញពីខួរក្បាលគាត់អស់ មីងព្រាបអង្គុយយំហ៊ូៗដូចកូនក្មេង គាត់នឹកខ្លាចជាប់គុកជា ក្រោយនឹកអាណិតប្ដីស្ដាយទ្រព្យសម្បត្តិគោក្របីដែលត្រូវបង់ខាតទៅលើកន្ទុយលេខ ។ មីងព្រាបលើកដៃសំពះប្ដី និយាយទាំងទឹកភ្នែកហូរ សស្រាក់ថា :

-ខ្ញុំដឹងខ្លួនខុសហើយពុកវា...! សព្វថ្ងៃយើងធ្លាក់ខ្លួនក្រ ជំពាក់គេរុំកោះ អស់គោក្របី អស់ទាំងដីស្រែកេរ្ដិ៍អាករពីដូនពីតា មកតែពីអា កន្ទុយលេខ!ពីថ្ងៃនេះទៅខ្ញុំសូមស្បថស្បែលែងជឿចំណោទ លែងជឿយល់សប្ដិអីទៀត ហើយចំពោះអាសេងលីមេកន្ទុយលេខធំខ្ញុំត្រូវតែប្ដឹង រាជការឱ្យអូសក្បាលវាទៅញាត់គុក តែទុកឱ្យវានៅធ្វើមេកន្ទុយលេខ ទៀតអ្នកស្រែខ្លះដែលមិនទាន់ភ្ញាក់ខ្លួន មុខជាត្រូវហិនហោចដោយសារ វាមិនខាន ...!

ពូព្រើល ដល់ឃើញប្រពន្ធយំទទួលសារភាពខុស គាត់ក៏អត់ទោសឈប់ក្រេវក្រោធ បែរជាអាណិតប្រពន្ធខ្លះៗឡើងវិញ :

-អើ ! បើដឹងខ្លួនយើងខុសហើយ ម្ទីម្នាកែប្រែចិត្តគំនិតមកជាអ្នករកស៊ីត្រឹមត្រូវ ឱ្យសមជាពលរដ្ឋថ្លៃថ្នូរនៃប្រទេសឯករាជ្យទៅយើង ចាស់សក់ស្កូវហើយ ! បើរាជការចាប់បានជាប់គុកច្រវាក់ តើគ្រួសារវេទនាយ៉ាងណា ? តើអ្នកណាគេសមមុខ ?

ពូព្រើលឈប់ស្ងៀមបន្តិច គាត់ក៏បន្តវាចាទៀតថា :

-អញមិនហាមឃាត់ទេការផ្សងជោគវាសនា ! ឆ្នោតជាតិ មានទិញទៅចុះមួយលើកពីរបីសន្លឹក វាអស់លុយតិច បើវាសនាយើងមាន ត្រូវមកក៏ច្រើន បើថាវាខុស ក៏ទុកដូចជាយើងជួយជាតិ ...!

ការឈ្លោះប្រកែករវាងពូព្រើលមីងព្រាប ក៏សន្មតថាចប់ត្រឹមហ្នឹងដោយខាងមីងព្រាបទទួលសារភាពខុសគ្រប់បែបយ៉ាង

ព្រឹកស្អែកឡើង នាយព្រឹលមិនបានទៅជួបនាងធឿនតាម សន្យាទេចៅទំពែកដេកចង្ហៃងទាល់តែថ្ងៃចាំងគូថទើបក្រោក។ នាយ យើងដើរទៅអង្គុយសំកុកនៅជើងក្រានបាយមុខក៏មិនលប់សក់ទុកឱ្យ បះសើងមមើងមិនរវល់អើពើនឹងសិត ។

ពូព្រើលមីងព្រាបដើរមកឃើញ ក៏កើតមានក្តីសង្ស័យ ។ ជាបន្ទាន់ មីងព្រាបក៏សួរទៅកូនកម្លោះទាំងងឿងឆ្ងល់ថា :

-ឯងកើតអីកូន ម្តេចក៏មិនទៅលប់លាងមុខមាត់ ថ្ងៃនេះឯងមិនទៅស្រែទេឬ ?

ពូព្រើលជួយនិយាយបន្ថែម :

-អើ ! បើក្នុងខ្លួនវាមិនស្រួល ថ្ងៃនេះមិនទៅស្រែក៏បានដែរ លប់លាងមុខរកទិញថ្នាំលេបសម្ងំដេកវិញចុះ ! ....

-ខ្ញុំអត់កើតអីទេពុក ...ម៉ែ ...!

នាយព្រឹលនិយាយសម្លេងដើមក រកកលចង់យំ ។

-បើឯងមិនកើតអី ម៉េចក៏អង្គុយមុខស្មោរមើលតែមាន់ធ្លាក់ទឹក ហើយរកកលចង់យំ ?

ពូព្រើលសួរ ។

-បាទ ! ខ្ញុំមិនសប្បាយចិត្តពុក ...

-ឯងមិនសប្បាយរឿងអី ! មិនសប្បាយរឿងម៉ែឯង និងអញឈ្លោះគ្នាម្សិលមិញឬ ?ហា ! ហា ! (ពូព្រើលសើចដោយកាត់យល់ថា នាយព្រឹល មិនសប្បាយចិត្ត មកពីគាត់ឈ្លោះនឹងប្រពន្ធ)ឃើញទេម៉ែវា! គ្រាន់តែយើងឈ្លោះប្រកែកគ្នាបន្តិចបន្តួច កូនចៅវាទៅជាអង្គុយកើតទុក្ខ !

-មិនមែនរឿងហ្នឹងទេពុក ! ម៉ែនិងពុកចង់វាយគ្នាបែកក្បាលហូរឈាមក៏ខ្ញុំមិនឈឺក្បាលដែរ តែនេះវាជារឿងផ្ទាល់ខ្លួនរបស់ខ្ញុំ ....

-អូ ! ឯងមិនមែនកើតទុក្ខរឿងអញនិងម៉ែឯងទេ ? (ពូព្រើល ចងចិញ្ចើម ) បើតចឹងឯងកើតទុក្ខរឿងអីទៅចុះ ...!

នាយព្រឹលអង្គុយអេះអុញ កេះក្រចកមួយស្របក់ធំ ទំរាំដាច់ចិត្តជំរាបឪពុក :

-ខ្ញុំ ...ខ្ញុំ ! ចង់បានប្រពន្ធពុក !

-យី ! ឯងចង់បានប្រពន្ធ ! ( មីងព្រាបឧទានតិចៗ ទ្រង់ភ្ញាក់ ) ពុទ្ធោអើយ ... ! គ្រាន់តែចង់បានប្រពន្ធអង្គុយធ្វើមុខងាប់ដូចគេយកទៅចងបាញ់ ! ឯងស្រឡាញ់កូនអ្នកណា ?

-បាទ ! ស្រឡាញ់នាងធឿន កូនពូញ៉ៅមីងឡឹកនៅភូមិឯត្បូង ណ៎ាម៉ែ .

-អ៊ឺម៉ី ... អស្ចារ្យណាស់កូនប្រុសម្ដាយ ! ( មីងព្រាបដែរទៅសួរយោបល់ប្ដី រឿងហ្នឹងគិតលៃលកយ៉ាងម៉េចទៅពុកវា ? )

ពូព្រើល កេះដែកភ្លើងអុជបារីស្លឹកសង្កែបឺតបង្ហុយផ្សែងមួយដង្ហើមធំទើបឮគាត់និយាយទៅប្រពន្ធថា :

-ចាំបាច់គិតគូរអីឱ្យវែងឆ្ងាយ ! បើវាចង់បានប្រពន្ធយើងចូលស្ដីដណ្ដឹងរៀបការឱ្យវាទៅ ។

នាយព្រើលឮឪពុកនិយាយដូច្នោះ ក៏មុខឡើងឈាមរីកថ្លា ស្រស់បន្តិច ។

-អារឿងចូលស្ដីដណ្ដឹងខ្ញុំចេះតែធ្វើបាន! ( មីងព្រាប និយាយ ) តែបញ្ហាលុយកាក់ឯណោះ ឯងជួយគិតខ្ញុំមើល៍ ...?

-មិនចាំបាច់គិតទេ ! លុយកាក់យើងធ្លាប់បង់ខាតទទេៗរាល់ម៉ឺនគ្រាន់តែរកលុយការប្រពន្ធឱ្យកូនមួយមិនបាន ! ស្រែនៅក្រឡោមភ្លុក នៅអូរគ្រៀតឆ្នាំនេះយើងមិនបាច់ធ្វើទេ លក់ឱ្យគេចុះ ទុកតែកូនស្រែ កំពកពីរបីក្បែរផ្ទះគ្រាន់យកស្រូវស៊ីខួបប្រាំង ខួបវស្សាបានហើយ ។

ការជជែកពិភាក្សារវាងពូព្រើលមីងព្រាប ក៏បានទៅដល់ទីបញ្ចប់ដោយពូមីងស្របមតិគ្នាថានឹងចូលស្ដីដណ្ដឹងនាងធឿនឱ្យនាយ ព្រើលនៅពេលឆាប់ៗ ។

នាយព្រឹលឬកម្លោះក្បាលទំពែកយើង មានចិត្តសោមនស្សជាអតិបរមា។ អ្នកឱនក្រាបសំពះបាទជើងអ្នកឱ្យកំណើតទាំងពីរព្រមទាំងសួរទៅឪពុកថា :

-អត់ទោសលោកពុក ! បើលោកពុកអាណិតមេត្តារកប្រពន្ធឱ្យកូនហើយ សូមលោកពុកជួយបង្រៀនវិធីស្នេហាឱ្យកូនចេះផង សព្វថ្ងៃកូនទៅល្ងង់ណាស់ក្នុងរឿងនេះ !

ពូព្រិលគ្រវីក្បាល ដកដង្ហើមធំ នឹកហួសចិត្តនឹងសំដីកូន

-អស្ចារ្យណាស់កូនព្រឹល ! អ្នកណាគេដែលទៅរៀនវិធីស្នេហា មើលតែរៀនអក្សរលេខក្បួនទាយទន្តនោះ កាលអញនិងម៉ែឯងបានគ្នា ក៏អញគ្មានទៅរៀនវិធីស្នេហាសេហ្នហឹតអីដែរ គឺធម្មជាតិតាក់តែងសត្វលោកកើតមកឱ្យចេះគ្រប់ៗគ្នា ដោយមិនចាំបាច់រៀនឯងសុំរៀនរបៀបនេះ អញមិនចេះបង្រៀនទេ ! ...

-ពុក និងម៉ែនៅល្ងង់ណាស់...! (នាយព្រឹលនិយាយដោយមិនអស់ចិត្ត) ព្រោះតែពុកនិងម៉ែមិនចេះតចឹងហើយ បានជាកើតខ្ញុំមកក្បាលទំពែកខុសគេខុសឯង ខ្ញុំមិនជឿសោះថា ស្នេហាគ្មានក្បួន អាអន្ទិតសន ប្ដីនាងរ៉ន វាប្រាប់ខ្ញុំថាស្នេហាមានក្បួនរបស់គេត្រឹមត្រូវកាលមុនការ វាទៅលេងភ្នំពេញវាទិញបានទាំងរូបថតមកទៀតផង ទាំងអស់មានជាងសាមសិប តែមិនដឹងសាមសិបប៉ុន្មានទេ ព្រោះវា មិនព្រមឱ្យខ្ញុំសុំមើលសោះ ! ...

-អើ ... ! អញអ្នកស្រែអ្នកចំការ ធ្វើម្ដេចវានឹងចេះសព្វគ្រប់ បើថាអាអន្ទិតសនវាមានរូបថតពន្យល់របៀបស្នេហា ឯងសុំទៅរៀនពី វាទៅខ្ចីវាយកទៅស្រុកមោងឱ្យផ្ទះថតរូបគេថត ចម្លងមករៀនតែពីរបី ថ្ងៃវាចេះទៅហើយ ..

ពូព្រើល ដាក់សម្លេងទន់ និយាយវាយស្រេបនឹងយោបល់កូន ។

នាយព្រឹលថ្ងៃនេះមានអាការៈរីករាយស្រស់ស្រាយប្លែកពីប្រក្រតី ។ ក្រោយពីស្កាត់ទៅជួបនាងធឿនសុំខមាលទោស អំពីដំណើរយូរមិនបានមកជួបតាមកំណត់សន្យាហើយនិយាយរឿងរ៉ាវឪពុកម្ដាយខ្លួនព្រម ចូលស្ដីដណ្ដឹងសព្វគ្រប់នាយយើងក៏លានាងធឿនទៅផ្ទះអាន្ទិតសនជាបន្ទាន់ ។

-៤-

ចង់ចេះស្នេហាទាល់តែរត់មិនសព្វដី

គិតទៅស្នេហានៃមនុស្សលោក ចំជាស្មោកគ្រោកហួសនិស្ស័យ
ថតរូបផ្ដេសផ្ដាសលក់បានថ្លៃ អន្ទិតសនសក់ខ្វិទិញធ្វើគ្រូ ។
នាយព្រឹលហេតុតែចង់ចេះពេក លួចមើលគេដេកហាត់គឃ្លូរ
ម្ចាស់គេភ្ញាក់ទាន់ដេញចាប់ព្រួ ស្នេហាមានគ្រូរត់មិនសព្វដី ។

នាយព្រឹលទៅដល់ផ្ទះអន្ទិតសន ក៏ត្រូវពេលល្ងមដែលគេកំពុងរៀបចំទទួលទានបាយ ។ ក្នុងឋានៈជាមិត្តភ័ក្តរួមវត្តជាមួយ អន្ទិតសនបានហៅនាយព្រឹលឱ្យទៅរួមបរិភោគយ៉ាងស្និទ្ធស្នាល ។

លុះបាយរួច ស៊ីចេកលាងមាត់ ផឹកទឹកហើយ អន្ទិតសនក៏ហៅសម្លាញ់ទៅអង្គុយលេងរានហាលខាងមុខផ្ទះយកខ្យល់អាកាស ។

-ឯងមកលេងនឹងអញនេះមកធម្មតាទេ ឬក៏មានការណ៍ អ្វីដែរ ? អន្ទិតសនសួរ ។

-អើ ថាគ្នាមកលេងក៏ដូចជាមកមានការតថឹងដែរ ! មកនេះគឺ គ្នាមានរឿងចង់ពិគ្រោះនឹងឯងបន្តិច ។

-រឿងអ្វីទៅ និយាយមកមើល ?

-គឺថា ! ...គ្នាជិតការប្រពន្ធដូចឯងហើយ ...នាយ ព្រឹលឈប់ លេបទឹកមាត់ផ្អើមបំពង់កបន្តិច ទើបបន្តវាចាតទៅទៀត :

-សូមឯងអាណិតឱ្យអញ សុំខ្ចីរូបថតបង្រៀនវិធីស្នេហាដែល ឯងទិញពីភ្នំពេញមកចែកឱ្យអញរៀនផង ! ហើយរាត្រីផ្សំដំណេកដំបូង ឯងនិងប្រពន្ធឯងធ្វើយ៉ាងម៉េចខ្លះ បានជាសព្វថ្ងៃ ប្រពន្ធឯងសាច់ឈាមថ្លាស្រស់ទ្រគាកឡើងរីកអន្ទីលល្អម្ល៉េះ ?

និមិត្តតែបានឮពាក្យនេះកាលណា ឱរ៉ានាយសនក្តៅស្ទើរឆេះ ។ នាយយល់ថា ការដែលនាយព្រឹលហ៊ានមកសួរដូច្នេះ ជាការមាក់ងាយ ខ្លួននិងប្រពន្ធខ្លួនហួសនិស្ស័យ ។

-នែ ! អាព្រឹល ! ( អន្ទិតសនចង្អុលមុខ ) អាឯងស៊ីបាយអញមិនទាន់ស្រកពោះផង អាឯងហ៊ានពោលពាក្យលែបខាយ មើលងាយអញ និងប្រពន្ធអញទៀត ម្តងនេះអញឈប់រាប់រកឯងជាមិត្តភ័ក្តហើយ ! ត្រូវអាឯងដឹងខ្លួនដើរចុះចេញពីផ្ទះអញភ្លាមទៅ !

-យី ! ឆ្កួតទេដឹងអាសន ! អញគ្មានចេតនាមើលងាយ មើលថោកអានិងប្រពន្ធអាទេ អញដឹងថាឯងមានក្បួនខ្នាតស្នេហា បានជាអញខំស្កាត់មកសួររកសុំរៀន ម្តេចក៏អាយល់ច្រឡំថាអញមើលងាយទៅវិញ ?

-កុំបាច់ដោះសារអាព្រឹល ! យើងសុទ្ធតែធ្លាប់បានបួសរៀនប្រាំមួយប្រាំពីរប្រយោគរួចមកហើយស្គាល់ណាស់ ! យល់ណាស់ ! ពាក្យ ណាល្អ ពាក្យណាអាក្រក់ អញរាល់ថ្ងៃរាល់យប់មានសេចក្ដីសុខជាមួយប្រពន្ធ ក៏ដោយសារតែរូបថតជាងសាមសិបសន្លឹកហ្នឹង ! អញទំរាំតែរកទិញបាន គេចពីមុខគិញមុខប៉ូលិសហត់ចង់ស្លាប់ ! បើអញឱ្យអាឯងទៅ ដូចជាអញឱ្យប្រពន្ធស្រោតសំពត់អស់ពីខ្លួនឱ្យអាឯងមើលទៅហើយ !

-អញសុំខ្ចីយកទៅឱ្យគេថតចម្លងកន្លះថ្ងៃសិនមិនបានទេឬ ?

នាយព្រឹលខំប្រឹងនិយាយអង្វរឱ្យអន្ទិតសនអាណិត តែអន្ទិត សនរាដៃបដិសេធដាច់អហង្កាមកវិញថា :

-ទេ ! ទេ ! កុំសូម្បីឡើយឯងខ្ចីកន្លះថ្ងៃ គ្រាន់តែសុំមើលមួយភ្លែតក៏អញមិនឱ្យដែរ ! ចុះពីផ្ទះអញទៅអាមិត្តលូកថ្លើមមិត្ត ! ...

នាយព្រឹល ឃើញថាអស់ផ្លូវនឹងអង្វរកសុំមើលរូបថតពីអន្ទិត សនហើយ ចៅទំពែកក៏ដើរទន់ករងៀក នាំយកទាំងសេចក្ដីសោកសៅអស់សង្ឃឹមត្រឡប់ទៅផ្ទះ ។

រាត្រីនេះជារាត្រីខាងរនោច ឃុំព្រៃស្វាយទាំងមូលគ្របដណ្ដប់ទៅដោយផ្ទៃអន្ធការងងឹតសូន្យសុង នៅលើមេឃាឃើញតែពន្លឺផ្កាយព្រិចៗ ។ សម្លេងឆ្កែលូងចចុងភូមិឮសូរគ្រលួចអណ្ដែតតាមរលកខ្យល់ ។

នៅក្រោមដើមជម្ពូ មុខផ្ទះមេស្រុកគាំ ស្រមោលមនុស្សមួយរូបឈរសម្ងំស្ងាត់ស្ងៀម បង្កប់ខ្លួនបាត់នឹងផ្ទៃងងឹតយូរៗគេឃើញមនុស្សអន្ធការនេះក្រឡេកមើលទៅលើផ្ទះមេស្រុកគាំម្ដងៗ ។

តើមនុស្សចម្លែកនេះជាអ្នកណាទៅអេះ? ហើយគេមកឈរធ្វើអ្វីក្រោមដើមជម្ពូយប់យន់ថ្មើរនេះ ? ប្រហែលជាពួកចោរ ហានរុំបំរុងចូលមកលួចគោមេស្រុកគាំទេដឹង? ដើម្បីបំបាត់អាការងឿងឆ្ងល់អ្នកនិពន្ធខ្ញុំសូមជំរាបអស់លោកអ្នកអានឱ្យបានជ្រាបថា ស្រមោលមនុស្ស ដែលយើងឃើញអំបាញ់មិញមិនមែនជាអ្នកណាក្រៅពីនាយព្រឹលឡើយ ។

នាយព្រឹល កាលបើទៅដល់ផ្ទះ ក៏កើតទុក្ខអង្គុយមិនសុខដេក មិនលក់តប់ប្រមល់រសេះរសោះដៃជើងដូចមនុស្សទើបងើបពីឈឺ ។ ជីវិនចិត្តចៅមាណពផ្តោតជាប់ទៅតែលើរូបថតអន្ទិត សន បើពុំបានរូបថតមើលជីវិតអាពាហ៍ពិពាហ៍របស់គេ ក៏ប្រហែលមិនបានជួបនូវរសជាតិស្នេហាដ៏សែនឈ្ងុយឆ្ងាញ់ដែរ ។ ម្ល៉ោះហើយទ្រាំលែងបាន នាយព្រឹល ក៏ដាច់ចិត្តប្រថុយមកផ្ទះអន្ទិត សនទាំងយប់អធ្រាត្រ ប្រាថ្នាមកលួចលបមើលរបៀបស្នេហារវាងអន្ទិតសននិងនាងរ៉ែនតើគេស្ទាត់ជំនាញយ៉ាងណា បានជាគេទាំងពីរនាក់ប្តីប្រពន្ធបែកសាច់បែកឈាមថ្លាស្រស់ល្អខ្លាំងម្ល៉េះ ។

កាលបើឃើញស្វាត់មាត់មនុស្ស ចង្កៀងធំក្នុងផ្ទះពន្លត់ហើយ នាយព្រឹលក៏ដើរសរសៀ១ ឯបខ្លួននឹងគុម្ពផ្កាចុចកែងជើងស្រាល១តំរង់ ទៅបន្ទប់ដេកអន្ទិតសន។ រាប់ថាជាគ្រោះល្អ ភ្លែពីរដេកនៅមាត់ជណ្តើរ ពុលបាយជ្រូកពីល្ងាច ដេកស្តូងស្តឹងលែងកំរើកប្រាណ ។ អន្ទិតសនមិន ទាន់ដេកទេចង្កៀងប្រេងកាតក្នុងបន្ទប់ ធ្វើឱ្យនាយយើងដៀងភ្នែកម្ខាង មើលតាមប្រហោងក្តារឃើញខាងក្នុងយ៉ាងច្បាស់ទែង ។

អាអន្ទិតសន ដេកមើលសាស្ត្រារឿងទុំទាវឱ្យប្រពន្ធស្ដាប់ ចំណែកនាង រ៉ែនត្រចៀកផ្ទៀងស្ដាប់ ដៃប៉ាស់ជុលសំពត់អាវចាស់ៗទុកស្លៀកទៅធ្វើស្រែ ។ ពេលមួយនាងរ៉ែនក៏សួរទៅប្ដីថា :

-បងអ៊្ហា...! កាលបងនៅបួសបងមានលួចគួចក្នុងចិត្តស្រឡាញ់ស្រីដូចជានេនទុំស្រឡាញ់នាងទាវដែរឬ ?

-អត់ទេអូន !

អន្ទិតសនឆ្លើយ ។

-ហ៊ឹះ ! ខ្ញុំមិនជឿបងទេ ... បើបងមិនស្រឡាញ់ ! ម្ដេចក៏ពេលភ្ជុំម្ដងៗ ខ្ញុំយកចង្ហាន់ទៅប្រគេន ក៏បងលួចសម្លឹងខ្ញុំ ?

អន្ទិតសនដាក់សាស្ត្រាចុះ បែរមកសើចដាក់ប្រពន្ធ ហើយនិយាយថា :

-ធម្មតាទេអូន ! កាលណាគេយកចង្ហាន់ទៅប្រគេន លែងអីនឹង គន់មើលខ្លះ មើលនេះមិនមែនបានសេចក្ដីថាស្រឡាញ់ទេ ! គឺមើលក្នុងឋានៈថ្លែងអំណរគុណនិងជូនផល្លានិសង្សដល់ឧបាសក ឧបាសិកាទេតើ? លោកសង្ឃដូចនេនទុំដាច់អាប័តនីខាងផ្លូវសាសនាខ្លាំងណាស់ ស្លាប់ទៅបើតាមធម៌ព្រះគឺប្រាកដជាទទួលបាបធ្ងន់ មិនបានទៅកើតនៅឋានសួគ៌ទេ ហើយលោកសង្ឃរបៀបនេនទុំក៏មានតែនៅក្នុងសាស្ត្រារឿង ទុំទាវមួយប៉ុណ្ណោះ ..

នាងរ៉ែន រុញកន្ត្រាំងដេរទៅគៀនជញ្ជាំងប្រាសខ្លួនដេកជិតប្ដី ហើយក៏ប្រែបទសន្ទនា :

-បងអ៊្ហា ! អូនងងុយគេងហើយ បងយករូបថតមកបង្រៀនអូនទៀតមើល !

នាយព្រឹលឈរលបមើលពីក្រៅព្ធសំដីនាងរ៉នបុកពោះភឹបៗ ខំបើកភ្នែកធំៗប្រុងចាំមើលរូបថត ។ អន្ទិតសនយករូបថតជាងសាមសិបសន្លឹកមករាយលើគ្រែដូចគេហាលសន្លឹកបៀ ។ នាយព្រឹលឃើញរូប ថតទាំងនោះញ័រដៃញ័រជើងចង់ទៅជាខ្យល់គ នាយយើងខំប្រឹងទប់សតិអារម្មណ៍មិនឱ្យរំភើបហួសហេតុ ដោយចាំមើលតើអន្ទិតសនវាយករូបថតស្រមេមស្រមាមអស់នេះ មកបង្រៀនប្រពន្ធរបៀបណា ?

អន្ទិតសនសើរើរើសមួយសន្ទុះ ទើបព្ធមាត់និយាយទៅកាន់ប្រពន្ធថា :

-ដីរិចុះព្រេង អន្ទង់ឈ្លក់ទឹក ត្រីប្រមាហែលគោកនង្គ័លបាក់ផាល សុទ្ធតែរៀនរួចហើយ យប់នេះបងនិងនាំទៅលេងឋានសួគ៌ម្តង គឺ យើងទៅជាមួយអណ្តើកឆេះស្នូក ...

ថាហើយ អន្ទិតសនហុចរូបថតមួយសន្លឹកទៅឱ្យប្រពន្ធមើល ។

នាងរ៉ន គ្រាន់តែមើលបន្តិច ក៏ដូចជាត្រូវមន្តសន្តំនៃក្រុងមារកម្ពុទ្ធយក្សា ថ្ពាល់ឡើងក្របាមរលោងបបូរមាត់ញ័រទ្រើកៗ ដូចស្កន់ ទាញភ្នែកទាំងពីរមមីរបើកលែងចង់រួច ។ នារីឈោងដៃទៅឱបកប្តី និយាយសម្លេងខ្សាវៗរបៀបមនុស្សរៀបដាច់ខ្យល់ :

-បងសនអ្ហា ...! បងគឺជាកំពូលប្តីសម្លាញ់របស់អូនមែន .... បងប្រសប់លួងលោមប្រពន្ធណាស់ ...! បងគិតនាំអូនទៅលេងឋាន សួគ៌ឥឡូវឬ ...

អន្ទិតសនមិនទាន់ឆ្លើយទៅប្រពន្ធភ្លាមទេ អន្ទិតយើងទាញខ្លួនប្រពន្ធមកឱបថើបញ្ជក់ញី ចាប់នេះច្បិចនោះ អស់ចិត្តអស់ចង់ទើបថ្លែង វាចាទៅនាងរ៉ន :

-បិទភ្នែកទៅអូន ...! យើងទៅដល់ឋានសួគ៌ឥឡូវហើយ ....!

អន្ទិតសន ចាប់ផ្ដើមប្រកបកាមកិច្ចជាមួយភរិយាដូចជាសព្វ មួយដងពុំបានដឹងខ្លួនថាពេលនេះមានគេលួចលបមើលពីខាងក្រៅឡើយ ។

និយាយពីនាយព្រឹលវិញ ឈរលួចមើលគេពីខាងក្រៅបុកពោះភឹបៗ ភ័យផងស្រួលផងច្របល់គ្នា ។ សព្វសាពាង្គកាយបែកញើសប៉ុនៗ គ្រាប់ពោត អន្ទិតសននឹងនាងរ៉ែនកំពុងកាន់ដៃគ្នាទៅសោយសុខឯឋានសួគ៌ ចំណែកចៅមាណពទំពែកក្បាល ក៏កំពុងបណ្ដែតអារម្មណ៍ទៅឋានសួគ៌នឹងគេនឹងឯងដែរ ។ ទ្រាំឈរសំរក់ទឹកមាត់តទៅទៀតលែងកើត នាយព្រឹលភ្លេចខ្លួនមិនបានជាគិតថាខ្លួនកំពុងលបមើលគេក៏ស្រែកឡើង ខ្លាំងៗដោយពីសតណ្ហាស្ទុះកញ្ច្រោលហួសកំរិត

-លោកអើយ ! បែកទ្រូងខ្ញុំស្លាប់ឥឡូវ ហើយឥចឹងទេតើបានជាគេចូលចិត្តយកប្រពន្ធ ... !

សម្លេងនាយព្រឹល បានទៅកន្ត្រាក់សោតិន្ទ្រិយារម្មណ៍គូស្វាមីភរិយាឱ្យភ្ញាក់រន្ធត់ធ្លាក់ពីលើឋានសួគ៌មកដីវិញមួយរំពេច ។

-ចោរ ! ចោរ ! ចោរលួចចូលផ្ទះ ! ពួកយើងព័ទ្ធចាប់វាឱ្យបាន ! អន្ទិតសនស្រែកហៅគេឯងអ្នកនៅក្នុងផ្ទះឱ្យជួយដេញចាប់ ។

ជាបន្ទាន់ ការកោលាហលក៏កើតឡើង មនុស្សក្នុងផ្ទះមេស្រុក គាំប្រមាណបួនដប់នាក់ ខ្លះកាន់ដំបង ខ្លះកាន់ផ្គាក់នាំគ្នារត់ទៅកន្លែង ដែលអន្ទិតសនស្រែក ។ នាយព្រឹលភ័យស្មើរលោះព្រលឹង ហក់ប្រូស ពីលើផ្ទះមកពោរលើពាងទឹកមួយបែកខ្ចាយ ។ សុនខពីរពុលបាយជ្រូក ពីក្បាលល្វាចនៅមាត់ជណ្ដើរ

ភ្ញាក់ឡើងព្រួសដេញខាំនាយព្រើលប្រផុតប្រផើយ ។ ផ្អើលដល់អ្នកស្រុកជិតខាង ឈ្លួលពិលឈ្លួលចន្លុះដេញតាមកាប់ប្រកិត១គ្មានលោះលាត្រាប្រណី ។

-ពួកយើងស្ទាក់កាប់វាឱ្យបាន ! កុំឱ្យវារត់រួច ! អាចោរហ្នឹង ហើយ ដែលលួចគោអញពីឆ្នាំទៅ !

ពួកអ្នកស្រុកម្នាក់ ស្រែកបញ្ជាទៅគ្នាគាត់យ៉ាងក្តៅក្រហាយ ។ នាយព្រើលឮដូច្នេះ រិតតែភ័យបុកពោះ នឹកទៅដល់គុណម៉ែគុណឪឱ្យមកជួយក្នុងគ្រាមានអាសន្ន ។

នាយព្រើល រត់ទៅជាន់នឹងបន្លា បុកដើមឈើដួលបីបួនត្រឡប់ ។ ខ្លួនប្រាណមុតឆ្កូតចេញឈាមសស្រាក់ ។ កម្លោះអភ័ព្វប្រឹងរត់បានបួនដប់ស្រែ ក៏អស់កម្លាំងហោះទៅមុខលែងរួច ដួលដេកស្រប៉ាបលើផ្ទៃធរណី មាត់ទន្ទេញធម៌ទុកជាស្រេច គិតក្នុងចិត្តថារាត្រីនេះជីវិតអញមុខតែស្លាប់នឹងផ្លែផ្គាក់របស់អ្នកស្រុកពិតប្រាកដ ។

រីឯអ្នកស្រុក ប្រឹងដេញតាមនាយព្រើលប្រាំពីរប្រាំបីស្រែនៅ តែមិនទាន់ក៏នាំគ្នាឈប់ដេញដើរត្រឡប់មកផ្ទះវិញទាំងចងគំនុំអាឃាតព្យាបាទ ។

នាយព្រើល ក្រោយពីដឹងថាពួកអ្នកស្រុកត្រឡប់ទៅក្រោយវិញ ផុតគ្រោះថ្នាក់ហើយ អ្នកក៏ខំទប់អាត្មាដើរផងវារផងសំដៅទៅផ្ទះយ៉ាងទុព្វលភាព

% %

%

# ស្នេហាខ្វះថ្លៃផុតទូ

បានដល់ភ្នំពេញភ្លេចស្រុកស្រែ ភ្លេចឪភ្លេចម៉ែភ្លេចសង្សា
អាងប្រាក់មួយហ្វឹនចាយហ៊ុំហា លេងស្រីពេស្យាផ្សារស៊ីឡិប ។
ដល់ចោរលួចលុយខ្វះថ្លៃផ្ទុង ចិនទារឡុង៧ញ៉ូវទត្រិប
ប៉ូលិសអូសកចូលបកក្រិប ភិតភ័យស្ទើរស្លាប់បន់ម៉ែជួយ ។

ព្រឹកស្អែកឡើង ដំណឹងចោរលបឡើងផ្ទះមេស្រុក ក៏លេចឮខ្ចរខ្ចាយទាំងស្រុក ។ លោកមន្ត្រីប្រចាំឃុំបានបិទប្រកាស ហាមប្រាមដល់កូនស្រុក ឱ្យរៀបចំធ្វើរបងស្រោស់បន្លារៀងរាល់ផ្ទះ ខ្លាចក្រែងមានចោរក្មួញលបឡើងទៀត ដោយគ្មានអ្នកណាម្នាក់ចាប់ភ្លឹកនឹងសង្ស័យថា នាយព្រឹលឡើយ ។ មានតែអាអន្ទិតសនទេដឹងជាក់ថា នាយព្រឹលតែ នាយមិនចេញស្តីដោយគុំទុកក្នុងចិត្តថា ថ្ងៃណាមួយនឹងសងសឹកនាយ ព្រឹលវិញឱ្យទាល់តែបាន ។

មួយអាទិត្យកន្លងផុតទៅ នាយព្រឹលក៏បានសះស្បើយជាពីមុខរបួសពកមុខពកមាត់ដូចធម្មតាវិញ។ មីងព្រាបពូព្រើលទៅស្ទើរពាក្យស្តីដណ្តឹង នាងផឿនឱ្យនាយព្រឹលក៏បានដូចចិត្តប្រាថ្នា ។ ពូញៀៅមីងឡឹក យល់ព្រមលម្មចិត្តគ្មានចាំបាច់សាកសួររកខែឆ្នាំឱ្យគ្រូហោរគន់គូដូច ក្រមុំកម្លោះគេទៀតទេ គាត់គ្រាន់តែបង្គាប់មកខាងប្រុសបន្តិចបន្តួចតាមប្រពៃណី ហើយក៏កំណត់ពេលរៀបមង្គលការឱ្យថ្ងៃចូលស្តីដណ្តឹង នេះរួចស្រេចតែម្តង គឺថ្ងៃ១៣កើត ខែកត្តិក ខាងមុខនេះ ។

នាយព្រឹល សប្បាយចិត្តណាស់ លែងអៀនខ្មាស់ស្ទុះទៅចាប់ នាង ធឿន ឱបនាងធឿនឱបមុខមេបាចាស់ទុំទាំងសងខាង ។ មីងឡឹក សើចក្អៀក១ កាច់កកាច់ស្រងដាក់ដន្លងដោយឃើញកូនប្រុសស្រីចេះស្រឡាញ់គ្នា ។

នាយព្រឹល ឃើញទឹកមុខឪពុកម្តាយក្មេកក្នុងពេលអនាគត បែបរីករាយញញឹមញញែមមិនប្រកាន់ទោសអួសដំណើរនាយ យើងក៏រិតតែបានចិត្តក្បៀកដៃនាងធឿនដើរកាត់មុខភ្ញៀវពន្លឹចុះជណ្តើរតំរង់ទៅ គុម្ពោតព្រៃក្រោយផ្ទះប្រងើយ ។

-អូនធឿនអ៊្ហា ! អូនធឿនអ្ហើយ ...!

-ចំា .... បងព្រឹល !

-នៅតែ១៤ថ្ងៃទៀតទេ យើងទាំងពីរប្រាណបានទៅស្គាល់ឋានសួគ៌ដូចអនិ្ទតសននាងវ៉នហើយ ...

វាចាចប់ នាយទំពែកក៏យកច្រមុះបោលបុកផ្ទាំងថ្ពាល់ នាងធឿន ឮសូរគឺប ! គឺប ! ខ្សឺត ! ខ្សុត ! ខ្សុត ! ស្រង់យកជាតិក្លិនប្រហើរយ៉ាងក្រហល់ក្រហាយ ។

នាងធឿនបានគេបបោសអង្អែល ក៏ធ្វើឫកមាយាដកខ្លី គេចឆ្វេង គេចស្តាំ រើបំរះដូចជាមិនចង់ឱ្យនាយព្រឹលលួងលោម តែមិនបានប៉ុន្មាន ក៏ស្រោប់តែដួលផ្ងារស្រទាង ដេកកើយភ្លៅចៅមាណពបើកភ្នែកព្រឹម១និយាយចេញសម្លេងខ្សាវ១ថា :

-បងព្រឹលអ្ហើយ ... ! នៅ១៤ថ្ងៃទៀតដូចជាយូរណាស់ ! ចិត្តអូនចង់ឱ្យម៉ែឪរៀបការឱ្យហើយស្រេចក្នុងថ្ងៃនេះតែម្តង ... បំណាច់នឹងព្រមឱ្យយើង

រៀបការគ្នាជាប្ដីប្រពន្ធហើយ ចាំបាច់ទុកឱ្យយូរថ្ងៃរើសពេលរើសពេលា អីទៀត ហ្ន៎ ... ! គិតទៅចាស់ៗ ចំជាសូញសាញមែន ...!

-ចិត្តអូននិងបងមិនខុសគ្នាទេ...! អំណាចស្រឡាញ់អូន បងចង់តែយកអូនទៅនៅផ្ទះបងក្នុងថ្ងៃនេះផង ហើយបើសិនជាលេបបាន បងលេបអូនទុកក្នុងពោះឥឡូវហ្នឹង ... ព្រលឹងមាសស្នេហ៍ ... !

-បងចេះនិយាយពិរោះមែន ... សំដីបងមួយម៉ាត់ៗ ផ្អែម ដូចទឹកឃ្មុំ ជាតិនេះខ្ញុំសំណាងល្អណាស់ បានប្ដីប៉ះលើអ្នកកវីវោហា....!

នាយព្រឺល ត្រូវខ្យល់បញ្ជោរនាងធឿនសើចបញ្ចេញធ្មេញស្នាញ។ ដើម្បីឱ្យគេដឹងថាខ្លួនជាអ្នកកវីវោហាកាព្យឃ្លោង នាយក៏ខំរកនឹកពាក្យនិយាយយកឃ្លាចុងជួនទាំងត្រដាបត្រដួសថា

-កំណព្យកាព្យឃ្លោងយោងអាត្មា អ្នកបានសិក្សាទើបថាត្រូវ ... ខ្លះខំរៀនទាល់តែសក់ស្កូវ តែងកាព្យមិនត្រូវពីព្រោះអី ។ រូបបងក៏មិនមែនចេះឯង ស្រាប់បងរៀនក្បួនច្បាប់តាំងពីបាលីសំស្ក្រឹតឡាតាំងឥ.... រូមាំងថ្មីរបៀបថៃចង់ស្រីចេះបង្គួរ ! ឡាមួរៗ (L’AMOUR) គឺ ស្នេហា វរឡាៗ (Vorla) ថានុះន់! ដឺប៊ូៗ Debout ឱ្យក្រោកឈរ កាល់មីន អាស់ប្រូ (Kalmine-Aspro) ថ្នាំឈឺក្បាល ហា ! ហា !

នាយព្រឺល និយាយរួចក៏ខំប្រឹងសើចទាំងហាត់គឃ្លូរ ពើងទ្រូងទៅមុខ របៀបអ្នកអន្ទ្រើស ។ ឈប់មួយសន្ទុះបាត់ដង្ហក់ នាយព្រឺលក៏បែរទៅនិយាយជាមួយនាងធឿនដូចធម្មតាវិញ :

-បងពីរបីថ្ងៃទៀត គិតសុំពុកនិងម៉ែទៅភ្នំពេញទិញឥវ៉ាន់ការ ហើយតើអូនចង់ផ្ដែផ្ដាំឱ្យទិញអ្វីទេ ?

-អ៊ុំ ! បងទៅភ្នំពេញ ! (នាងធឿនឧទានតិច១ ដោយត្រេកអរ) បើបងទៅមិនចាំបាច់ឱ្យអូនផ្ដាំទេ របស់អ្វីក៏ដោយឱ្យតែបងទិញផ្ញើសុទ្ធតែពេញចិត្តអូនទាំងអស់ !

-ឥចឹងស្រួលហើយ របស់ណាបងពេញចិត្ត បងស្រឡាញ់ ចាំបងទិញមកផ្ញើ !

-អាព្រឹល ! អឺ ...អាព្រឹល យី ! អានេះវានាំគ្នាទៅឯណាឥចេះ ?

សម្លេងមីងព្រាបស្រែកហៅតាមបង្អួចពីលើផ្ទះ ។ នាយព្រឹលព្រួប្រញាប់ស្ទុះក្រោកម្ទីម្ទា ដឹកដៃនាងធឿន :

-ទៅផ្ទះវិញអូន ! ម៉ែបងគាត់ហៅហើយ ... ខ្ញុំនៅឯណេះ ! ខ្ញុំទៅហើយម៉ែអើយ !

ក្រោយពីនៅអង្គុយលេងសំណេះសំណាលបន្តិចមក ពូព្រើល មីងព្រាបនិងនាយព្រឹល ក៏លាម្ចាស់ផ្ទះត្រឡប់ទៅលំនៅដ្ឋានខ្លួនវិញ ។

..................................................................

ដូចអស់លោកអ្នកអានជ្រាបស្រាប់ហើយ នូវសណ្ដានចិត្តរបស់នាយ ព្រឹលនាយ ព្រឹលចង់ចេះចង់បានខ្លាំងណាស់រឿងស្នេហា រឿងរូបថត ។ ដូច្នេះកាលបើអស់សង្ឃឹមក្នុងការខ្ចីពីអាអន្ទិតសន ហើយមកគាប់ជួនខ្លួន ជិតរៀបការទៀត នាយ យើងយល់ថាត្រូវតែទៅភ្នំពេញ ទៅនេះប្រយោជន៏ទិញឥវ៉ាន់ មករៀបការផង ដើររកទិញរូបថត ដូចរបស់អន្ទិត សនផង។ នាយព្រឹលតាំងពីកើត

មករហូតសព្វថ្ងៃ មិនដែលបានស្គាល់ ទេទីក្រុងភ្នំពេញ ឮតែគេថាធំ ឮតែគេថាសប្បាយ ដូចឋានសួគ៌ ម្ល៉ោះហើយនាយយើងក៏អរផង ព្រួយផងច្របល់គ្នា ។

ល្ងាចនេះក្រោយពីស៊ីបាយទឹកឆ្អែតរួចរាល់ នាយព្រឹលក៏ដាច់ចិត្តនិយាយសុំទៅម្ដាយថា :

-ខានស្អែកខ្ញុំសុំម៉ែទៅភ្នំពេញហើយណាម៉ែណា ! ខ្ញុំទៅរកទិញ ខោអាវនិងឥវ៉ាន់មករៀបការ

-យី ! ឯងគិតទៅភ្នំពេញ ! ( មីងព្រាបបើកភ្នែកធំៗ ប៉ុនពងមាន់ ) ស្រុកគេធំណាស់រើយ ! តិចលោវង្វេងអត់បាយស្លាប់ អញតាំងពីកើតរហូតដល់ចាស់សក់ស្កូវ ជិតចូលរណ្ដៅស្អែកខានស្អែក អញមិនដែលស្គាល់យ៉ាងម៉េចទេ ! ឯងទៅឯងស្គាល់អ្នកណា ស្រុកគេធំណាស់ កុំទៅអីកូន !

-មិនអីទេម៉ែ ! យើងកើតមកជាកូនខ្មែរត្រូវតែស្គាល់រាជធានី ទីក្រុងរបស់ខ្លួន សូម្បីតែអាមេរិកកាំង បារាំង រុស្សីនៅម្នាក់មួយចំហៀង ផែនដី គេនៅមកលេងស្រុកយើងបានចុះយើងស្រុកយើងស្រាប់ យើងខ្លាចអី ខ្ញុំទៅមិនមែនអត់គ្នាឯណា ? ខ្ញុំទៅជាមួយអាគុច ដើរឡាន បាត់ដំបងភ្នំពេញពីដើមណាម៉ែ ...!

មីងព្រាប ត្រូវកូនបង្ហាញហេតុផលសព្វគ្រប់ គាត់ក៏លែងហ៊ានឃាត់គ្រាន់តែដាស់តឿន បន្តិចបន្តួចតាមរបៀបចាស់ទុំ :

-អើ ! បើទៅជាមួយអាគុចក៏ទៅចុះម៉ែមិនថាអីទេ តែឯងទៅឱ្យរវាសរវៃវិលមកវិញ ពីព្រោះថ្ងៃការនៅសល់តែជាងដប់ថ្ងៃទៀតទេ តើកូនទៅនេះត្រូវការលុយកាក់ស៊ីបាយ ធ្វើសោហ៊ុយ សោដាប៉ុន្មាន ?

នាយព្រឹលអង្គុយរាប់ដៃរាប់ជើងមួយសន្ទុះ ទើបនិយាយទៅកាន់ម្ដាយៈ

-មួយម៉ឺនមកបានហើយម៉ែ !

-មួយម៉ឺន ?

មីងព្រាបបញ្ជាក់សំដីកូន ។

-បាទ ! មួយម៉ឺនបានគ្រាន់ម៉ែ បើសល់ខ្ញុំមិនចេះយកមកផ្ទះវិញ ? ឬមួយម៉ែឯងមិនចង់ឱ្យខ្ញុំ ?

-មិនមែនឥចឹងទេកូន ! បានជាម៉ែសួរបញ្ជាក់ ព្រោះម៉ែមានលុយវាមិនគ្រប់ ... តែមិនអីទេ ! ស្អែកចាំម៉ែលក់គោមួយនឹមវាគ្រប់ ទៅហើយ ! ...

-បាទម៉ែ ... ខ្ញុំអរគុណម៉ែណាស់ ....!

នាយព្រឹល ស្ទុះទៅឱបម្ដាយថើបថ្ពាល់ខ្វងបីបួនខ្សឺតម្ខាង ដោយសេចក្ដីត្រេកអរ ។ មីងព្រាបសប្បាយចិត្តបានកូនប្រុសថើប អង្គុយញញឹម ហៀរទឹកមាត់ស្លាកាខ្លាក់ នឹកទៅដល់អតីតភាពកាលគាត់ទើបការរួចថ្មីៗ ប្ដីគាត់ក៏ថើបគាត់ញញឹមដូចជានាយព្រឹលអញ្ចឹងដែរ ។

ព្រឹកខានស្អែកឡើង នាយព្រឹលនិងនាយគុចក៏បានធ្វើដំណើរតាមរថយន្តឈ្នួលមួយមកភ្នំពេញ ។ ក្នុងឋានៈខ្លួនជាមគ្គុទ្ទេសក៍ នាយ គុចនាំនាយព្រឹលទៅជួលសណ្ឋាគារ(Hotel) មុំក្បែរផ្សារថ្មីសំណាក់ដើម្បីឱ្យស្រួលដល់ការដើរលេង ។

នាយព្រឹល ហេតុតែមិនដែលស្គាល់ទីក្រុងធំ ក៏ចេះតែដើរនឹកភ័យៗ និងឡានស៊ីក្លូប្រវាត់ច្រវែង ។ រីឯភ្នែកក៏គយគន់មើលហាងទំនិញធំៗមើលផ្សារថ្មីមើលផ្លូវថ្នល់ចាក់កៅស៊ូរាបរលើបរលោងជក់ចិត្តដិតអារម្មណ៍ ភ្លេចឃ្លានបាយ

ទឹក ។ ពេលល្ងាចត្រជាក់នាយគុច នាំទៅលេងតាមកន្លែងរមណីយដ្ឋាននានា ដូចជា មុខវាំង វិមានឯករាជ្យ, ពិព័រណ៍អចិន្ត្រៃយ៍នៃសង្គមរាស្ត្រនិយម, ស្ពានឆ្លងទន្លេទៅកោះជ្រោយចង្វា ពហុកីឡាដ្ឋានជាតិ (Stade Olympic) វត្តភ្នំ ។ល។ មួយថ្ងៃ .... ពីរថ្ងៃ បីថ្ងៃបានកន្លងទៅមុខយ៉ាងរហ័ស នាយព្រឹលឈ្លក់វង្វេងនឹងលំអទីក្រុង ភ្លេចស្រុកស្រែ ភ្លេចឪពុកម្ដាយគេ សប្បាយលែងគិតឃើញអ្វីទាំងអស់ តែចំពោះធឿនគួដណ្ដឹង នាយយើងនៅចាំជាប់ជានិច្ច ។

ម៉ោង៦ហើយ ...

បំផ្លូងអគ្គិសនីគ្រប់ដងវិថីក្នុងរាជធានី ឆេះភ្លឺព្រោងព្រាតតាមផ្ទះទំនិញនានាមានដាក់អំពូលពណ៌លឿង ខៀវ ក្រហម ស្វាយចំរុះគ្នា ។ មើលទៅសោភ័ណភាពរាត្រី ក្រុងភ្នំពេញពេលនេះប្រៀបបាននឹងឋាន កៃឡាស គួរ ជាទីត្រេកត្រអាលដល់អ្នកសញ្ចរទៅមកគ្រប់ប្រភេទ ។

នាយព្រឹល ឈរពីលើសណ្ឋាគារមើលមកក្រោមបណ្ដែតអារម្មណ៍ឱ្យរសាត់អណ្ដែតទៅតាមសោភ័ណភាពរាត្រីភ្លេចខ្លួនមួយខណៈ ។ នាយគុចនៅដេកលង់ទ្រនេសលើគ្រែមិនទាន់ភ្ញាក់ ដោយមកពីថ្ងៃផឹកសុរាស្រវឹងខ្លាំង ។ ចៅមាណពឈរបណ្ដែត អារម្មណ៍អស់រយៈពេលយូរក្រែលហើយក៏ដើរចូលទៅខាងក្នុងបន្ទប់វិញ ។

មួយសន្ទុះធំក្រោយមក នាយគុចក៏ភ្ញាក់ពីដេក ។ នាយ បែរទៅនិយាយជាមួយកម្លោះព្រឹល ដែលនៅអង្គុយជិតខ្លួនទាំងអាចម៍ភ្នែកពព្រាកថា :

-អញថ្ងៃម៉ិញផឹកស្រាជ្រុល ស្រវឹងដេកលក់ស្រួលដល់ហើយ អាព្រឹល !

-អើ ! អាឯងវាជ្រុលមែន (នាយព្រឿលនិយាយព្រមទាំងសម្លក់ នាយគុច ) ឱ្យតែបានផឹកមួយពេលបាយមួយដបរបៀបហ្នឹង ទំរាំដល់ថ្ងៃទៅស្រែវិញប្រហែលខ្វះថ្លៃឡានហើយអញ !

នាយគុចលើកដៃជ្រងសក់សើចហេះ ! ហេះ ! យកចិត្ត សម្លាញ់ :

-កុំនិយាយតចឹងអាម៉ាក ...! យ៉ងៗម៉ាខ្វ យូរៗមកភ្នំពេញម្តង កុំរៀនកំណាញ់ក្រៅតម្រានាំគេសើច ! ការស៊ីចាយ សប្បាយចិត្តវាជា ការធម្មតារបស់អ្នកទេសចរណ៍ទេ ! ថ្ងៃមុនកូនចៅកែឡានគេពឹងឱ្យអញជូនមកលេង គេឱ្យស៊ីផឹកច្រើនជាងអាបួនដប់សួនទៅទៀតគេមិន ដែលបានរអ៊ូរទាំដូចអាព្រឿលឯងទេ !

នាយព្រឿលឮដូច្នោះឡើងជំនោរភ្លែត ភ័យណាស់ខ្លាចគេដៀល ថាអ្នកស្រែកំណាញ់មិនបានស៊ីចាយ ភ័យខ្លាចអន់ថយជាងកូនចៅកែ ឡាន នាយយើងប្រញាប់ស្រាយទឹកមុខធ្វើជាញញឹមញញែមនិយាយលាងខ្លួនថា :

-អាគុចនិយាយដូចជាមិនធ្លាប់ស្គាល់ចិត្តអញ ! រឿងស៊ី រឿងចាយអញគ្មានឱ្យចាញ់អាណាមួយរៀលទេ តែដែលអញនិយាយនេះ គឺប្រយោជន៍កុំឱ្យឯងខូចសុខភាពដល់ឯងស្រវឹងខ្លាំងទៅបានអ្នកណាជូនអញដើរលេង ?

នាយគុចញញឹមប្រឹងបញ្ជោរថែម :

-អើអញធ្លាប់ដឹងចិត្តឯងវាសឿងតចឹងដែរ តែខ្លាចដល់ជិតមានប្រពន្ធកូនទៅ វាប្រែចិត្តគំនិត អារឿងដើរលេងឯងកុំភ័យ យប់នេះចង់ដើរលេងទើសភ្លឺសឹមដេកក៏បានដែរ ... ម៉ុងហ្វូទេ មួសាវ៉ាកញ៉ើងឡា !

-យើស ! ចេញវប្បធម៌បារាំងផងអាឆ្កែ !...

នាយព្រឹលសើច ដើរទៅយកបារីមកអុជជក់ហើយបន្តវាចាទៀតៈ

-នែ ! អាគុច ! យើងតាំងពីមកដូចជាមិនទាន់បានទៅលេង កន្លែងណាឱ្យវាសប្បាយជាប់ចិត្តជាប់ថ្លើមសោះ អញឮគេថាភ្នំពេញ មានស្រីៗស្អាតណាស់ណ៎ា ! សុទ្ធតែកូនកាត់យួន កូនចិនកន្ដាំងអីផង ម៉េចក៏អញដូចជាមិនទាន់បានប្រទះភ្នែកសោះឥចឹង ហើយអារឿងរូបថតក៏ដូចជាមិនទាន់កើតការអី ។

-អាព្រឹលឯងចង់លេងស្រីឬ ? ហ៊ឺ ! អានេះចំជាភ្លើមែន ថ្ងៃមុិញ ពីរបីនាក់ដែលឈរនៅមុខបន្ទប់យើងនុ៎ះអី !

-អ្ហ៎ ! ពីរបីនាក់ស្លៀកសំពត់ហូលថ្ងៃមុិញស្រីខូច ?

-អើ !

-យី ! អញកុំឱ្យតែបានដឹងអាចោរគេដោត ! អញឃើញវាដែរ អញខំដើរឱនៗកាត់មុខវា នឹកស្មានតែវាប្រពន្ធអស់លោកអ្នក ? ហើយអារឿងរូបថតដូចអញប្រាប់ឯងពីមុន យើងទៅរកទិញនៅហាងឯណា ទៅ ?

នាយគុចគ្រវីក្បាល នឹកហួសចិត្តនឹងសំដីភ្លីភ្លើល្ងង់គ្រប់ដប់របស់មិត្ត :

-រូបថតដូចឯងនិយាយប្រាប់អញហ្នឹង វាមានទាំងអស់៣៦ សន្លឹកអ្នកស្រុកភ្នំពេញគេហៅថា ហ្វូតូត្រង់ស៊ីសម៉ានីញៀរ (Photo trente six maniéres ) រូបហ្នឹងគ្រប់ហាងគេអត់ហ៊ានលក់ទេ ព្រោះ រាជការគេចាប់ គេថាវាជារូបអាសអាភាស វានាំឱ្យខូចសតិអារម្មណ៍ យុវជនយុវនារី តែគិញប៉ូលិសចាប់បានគឺត្រូវតែជាប់គុក ។

-ចុះម៉េចក៏អាអន្ទិតសនវាមកភ្នំពេញចេះទិញបាន ? វាប្រាប់អញថា រូបថតហ្នឹងជាក្បួនស្នេហាទំនើប មើលទៅនាំឱ្យយើងមាន សេចក្តីសុខ រីករាយ សប្បាយក្នុងចិត្ត ...?

-ហា ! ហា !ហា ! ( នាយគុចសើច ) ឯងនេះចំជាអាដំឡូង មូលមែន! អាអន្ទិតសនវាទិញបាន គឺវាទិញតាមពួកជ្វាដើរលក់វ៉ែនតា ស្រោមជើង នាលិកាតាមភោជនីយដ្ឋានធំៗ បើតាមអញដឹង រូបអស់ហ្នឹងវាមិនមែនក្បួន ស្នេហាទំនើបដូចអាអន្ទិតសនថាទេ តែបើឯងចង់បានណាស់ស្រេចចិត្តចុះ ចាំ ថ្ងៃស្អែកអញជួយរកទិញ ។

ការសន្ទនារវាងអ្នកទាំងពីរ ចេះតែប្រព្រឹត្តទៅក្នុងបរិយាកាស រីករាយ រហូតដល់ម៉ោង៧យប់ ទើបគេនាំគ្នាងូតទឹកជំរះរាងកាយ ។ ក្រោយពីបរិភោគ អាហាររួចហើយ នាយគុចក៏នាំនាយព្រឹលទៅរកកំសាន្តជាមួយពួកនាងរាត្រី នៅម្តុំផ្សារស៊ីឡិប

នាយគុចកាលដើមធ្វើព្រូឡានបាត់ដំបង ឱ្យតែត្រូវជើងឡាន ដេកបេន ភ្នំពេញ គេតែងតែមករកកំសាន្តកាយជាមួយពួកនារីទាំងនេះ ជួនកាលក៏ដេក ទាល់តែជិតដល់ពេលឡានចេញ ទើបភ្ញាក់ទៅតាមឡាន។ ញឹកញាប់រាប់មិន អស់ ពួកអ្នកធ្វើការឡានជាមួយគ្នាខឹងក៏នាំគ្នាទៅជំរាប ថៅកែៗក៏បញ្ឈប់ លែងឱ្យធ្វើការតទៅទៀតគឺដើមហេតុដែលបណ្តាល ឱ្យនាយគុចខានដើរឡាន ក៏មកតែរឿងដេកជាមួយសាហាយបេនឡាន ស៊ីឡិបនេះឯង ។

ផ្ទះដែលអ្នកទាំងពីរដើរចូលខណៈនេះ គឺជាផ្ទះអ្នកយ៉ែម មេសំផឹងធំ កូនចៅស្រីៗ របស់គាត់តែងហៅគាត់ថាម៉ែយ៉ែមៗ ម៉ែយ៉ែម ឬអ្នកយ៉ែមគ្រាន់

តែក្រឡេកឃើញនាយគុចភ្លាមក៏ស្គាល់ស្ទុះមកឱប ក្រសោបរាក់ទាក់ដូចសាច់ញាតិឃ្លាតគ្នាម្ភៃឆ្នាំកន្លងមកហើយមិនស្មើ ។

-យី ! បងគុចអើយបងគុច ! បាត់ទៅឯណាកន្លះឆ្នាំហើយមិន ដែលឃើញមកអើតសោះ អញ្ជើញអង្គុយៗ បងប្រុសខាងណោះ ! អ្នកយ៉ែមបែរមកគួរសមនឹងនាយព្រើល ។

នាយព្រើល រវល់តែទាក់ភ្នែកនឹងកូនចៅអ្នកយ៉ែម លុះឮសូរគេ អញ្ជើញខ្លួនក៏ភ្ញាក់ដូចគេកន្ត្រាក់ ដាក់គូថអង្គុយឆ្អឹងសម្ពឹងតទៅទៀត ។

-បងរវល់ពេកណាស់អូន បានជាមិនសូវបានមកលេងញឹកញាប់ ( នាយគុចនិយាយទៅកាន់អ្នកយ៉ែម ) ការរាជការឥឡូវតឹងតែង បងបន្ទិចលោកធំប្រើទៅមីស្យុង (Mission) ខេត្តនេះ ខេត្តនោះ ស្ទើរតែ រកពេលឈប់សំរាកគ្មានផង ...!

-ឥចឹងហើយបងអើយការរាជការ ...! ( អ្នកយ៉ែមនិយាយ ) កាលមុនបងប្រាប់អូនថាជិតឡើងសក្តិបី តើឡើងហើយឬនៅបង ?

-អ៊ូ ! ឡើងជាងបីខែហើយអូន ...!

នាយគុចនិយាយធ្វើវាហី ហាក់ដូចជាគ្មានអើពើនឹងឋានន្តរសក្តិ របស់ខ្លួន ។

នាយព្រើលអង្គុយស្តាប់គេនិយាយគ្នាចេះតែនឹកឆ្ងល់ក្នុងចិត្ត ៖ តើអាគុចវាធ្វើរាជការពីអង្កាល់ ? លោកសក្តិបីហ្នឹងសក្តិបីខាងណា ខាងទាហាន ឬខាងប៉ូលិស ? ទេ ! អាគុចវាព្រូឡានបាត់ដំបងទេតើ ? បើ ឥចឹងមានតែអានេះភរគេ អូ ! ប្រហែលស្រុកភ្នំពេញគេនិយមនិយាយ ភរភូតឥចឹងហើយមើលទៅ ?

កំពុងតែអង្គុយគិតភ្លេចខ្លួន នាយគុចក៏អូសទាញដៃឱ្យក្រោកឈរ ហើយណែនាំប្រាប់អ្នកយ៉ែមថា ៖

-នេះសម្លាញ់របស់បង គេធ្វើនាយមេព្រៃនៅស្រុកមោង

-ចាំ ! ត្រេកអរណាស់ដែលបានស្គាល់លោក ...

អ្នកយ៉ែមបែរមកចាប់ដៃនាយព្រឹលរបៀបបារាំង នាយយើង តាំងពីកើតមកធ្លាប់តែសំពះ ដល់មកឱ្យចាប់ដៃក៏ច្រឹមច្រាំ វារែកមិន ដឹងហុចដៃខាងណាទៅចាប់ ទីបំផុតក៏លូកដៃទាំងពីរទៅចាប់ដៃអ្នកយ៉ែមជាប់ នឹកក្នុងចិត្តថាបើខុសមួយក៏គង់ត្រូវមួយដែរ ។ ពួកកូនសំផឹងនៅក្នុងបន្ទប់ឈប់មើលឃើញថៅមេព្រៃក្លែងក្លាយ ចាប់ដៃម៉ែយ៉ែមរញ៉េរញ៉ៃខុសរបៀបដូចស្គន់ទាញ ក៏នាំគ្នាសើចគឹល ។ អ្នកយ៉ែម ខ្លាចថៅព្រឹលអៀន ប្រញាប់បែរទៅសម្លក់ឱ្យកូនចៅពួកស្រីៗទាំងនោះ ក៏នាំគ្នាក្ដោបមាត់ស្ងាត់ជ្រាបអស់មួយរំពេច ។

នាយគុច នាំនាយព្រឹលទៅអង្គុយក្នុងបន្ទប់ពិសេសមួយ ឆ្ងាយពីគេឯងដើម្បីកុំឱ្យថៅមេព្រៃយើងផ្អើលនឹងចលនារអ៊ូគគ្រុក កគ្រាក់ ។

ក្រោយពីបំប៉នស្រាឆ្នាខ្មៅ នាយព្រឹលស្រវឹងស្បែកមុខក្រាស់ដូចស្បែកក្របី ហើយនាយគុចក៏បញ្ជោរទៅអ្នកយ៉ែមថា ៖

-មើលកូន ! មានអាណាមកថ្មី ក្មេងហើយសាច់សស្អាតទេ យកបីបួនមកឱ្យសម្លាញ់បងវារើស !

-ចាំះមានបង ! ( អ្នកយ៉ែមឆ្លើយប្រញាប់ ) បងត្រូវការចិន ខ្មែរ ឬទេ? ពួកហ្នឹងសុទ្ធតែថ្មីៗទាំងអស់ !

-អើ ! កុំឱ្យចាស់គេ ថ្មីយើងណាំ !

នាយគុចសើចមើលមុខសម្លាញ់បន្តិច ទើបនិយាយតថា ៖

-យកទាំងបីទាំងបួនសាសន៍ហ្នឹងមក សម្លាញ់បងពេញចិត្តមួយណាស្រេចតែវារើស !

-ចាំបង (អ្នកយ៉ែមបែរទៅហៅស្រី១) នែ ! អារី ! អារិន ! សុខុម, សាខន, មាំឡា, កាពៅ, ល្អិត មកណេះ !

-ចាំ ! ម៉ែ ...!

ពពួកនារីបុប្ផាមាស ឆ្លើយព្រមគ្នាដូចគេណាត់ ហើយក៏រត់ស្រមកជុំវិញខ្លួននាយយើងទាំងពីរនាក់ ។

នាយព្រឹលបែបចង់ស្វាងស្រាក្រឡេកមើលទៅគ្មានទាស់ចិត្ត មួយណាសោះ ។ ភ្លើងស្នេហាឡើងកំដៅដល់៩៩អង្សា ផ្ទះអ្នកយ៉ែម ក្លាយទៅជាឋានសួគ៌ ស្រីទាំងអស់គឺប្រាកដនាងទេពអប្សរបវរកញ្ញាក្នុងការយល់សប្តិ ។ លែងនឹកនាដល់ឪពុកម្តាយ ស្រែចំការ សង្សារ គោ ក្របី នាយយើងនឹកឃើញតែម្យ៉ាង គឺពេលនេះគេកំពុងនៅឋានសួគ៌ ហែហមទៅដោយហ្វូងនាងទេពអប្សរ ហើយគេចង់នៅរបៀបនេះរហូតទាល់តែស្លាប់ មិនចង់ទៅស្គាល់ក្លិនអាចម៍គោ អាចម៍ក្របីក្នុងក្រោលទៀតឡើយ ។

-បងអ្នំា ... នៅអង្គុយសម្លក់សម្លឹងដល់ណាទៀត យប់ជ្រៅហើយបងមិនរងារទេឬ យកអូនទៅគេងឱបលេងមួយយប់ទៅបង អូននឹងធ្វើឱ្យបងមានសេចក្តីសុខទើសភ្លឺណ៎ា ...!

នាងមួយឈ្មោះសុខុមនិយាយរួច ក៏ស្ទុះទៅថើបឱបរឹត បំពក់ភ្លើងកាមរាគៈនាយព្រឹលឱ្យកាន់តែឆេះសន្ធោរព្រឹព្រួចស្រាវទឹកមាត់កាន់ តែខ្លាំងឡើង ។

នាយគុចដឹងអធ្យាស្រ័យរបស់មិត្ត ក៏ងាកមកឱនខ្សឹបដាក់ជិតរន្ធត្រចៀកនាយព្រឹលថា :

-យ៉ាងម៉េចសម្លាញ់ ! ឯងពេញចិត្តមួយណាចាត់ការភ្លាម១ ទៅយប់កាន់តែជ្រៅហើយ កុំឱ្យខាតពេលវេលាណា៎ ...!

-អញពេញចិត្តទាំងអស់ !

នាយព្រឹលឆ្លើយដោយមិនចាំបាច់គិត ។

-យី ! អាព្រឹល ! ឯងនិយាយលេងឬនិយាយមែន ? ស្រីទាំងអស់៧នាក់ក្នុងមួយយប់ឯងស្ទុះរួចឬ ?

នាយគុចប្រឹងសួរបញ្ជាក់ខ្លាចក្រែងសម្លាញ់ស្រវឹងស្រា និយាយមិនដឹងអី តែនាយព្រឹលនៅតែឆ្លើយខ្ជឹងដដែលថា :

-អញពេញចិត្តទាំងអស់ ! អញស្ទុះរួច !

-អើ ! បើឥចឹងអញសួរថ្លៃគេហើយវើយ !

នាយគុចនិយាយហើយ ក៏ដើរទៅជិតអ្នកយ៉េមសួរថ្លៃ :

-ឥឡូវសម្លាញ់បងវាថាវាពេញចិត្ត៧នាក់ហ្នឹង តើអូនឯង គិតប៉ុន្មាន ថាមកមើល ។

-ចា៎ះ ក្មាឯងមោយចាស់ សុំ៧នាក់ហ្នឹងពីរពាន់បានហើយបង ...

-នែ ! សម្លាញ់៧នាក់ហ្នឹង គេគិតក្នុងមួយយប់ពីរពាន់ តើឯង ថាយ៉ាងម៉េច ?

បើវាធូន់សោហ៊ុយពេកយកតែពីរនាក់ទៅបានហើយ ។

នាយព្រឹលកំពុងលង់ក្នុងសមុទ្រតណ្ហា ក៏ឆ្លើយធ្វើឫកខែង របៀបលោកធនបតីប្រាក់វាល់បាវថា :

-ពីរពាន់រៀល ! មិនមែនធំប៉ុនក្បាលដំរីទេអាសម្លាញ់ អាឯងហាមាត់សួរអញរបៀបហ្នឹងដូចជាអញវាអន់ពេក វត្ថុអ្វីឱ្យតែអញពេញចិត្តកុំថាឡើយត្រឹមពីរពាន់ឱ្យពីរពាន់ប្រាំផងក៏អញយកដែរ !

នាយព្រឹលនិយាយរួច ក៏ដកកាបូបស្បែកពីហោប៉ៅខោខាងក្រោយហូតក្រដាសប្រាក់ពីរខ្ទាស់បោះទៅឱ្យអ្នកយ៉ែម ។

-ហាក ! យកទៅចុះអ្នកស្រី !

-ចាំ ! ចាំ !

អ្នកយ៉ែម ស្ទុះទៅរើសក្រដាសប្រាក់មកញាត់ក្នុងហោប៉ៅដៃញ័រទទ្រើតដោយត្រេកអរ រួចហើយក៏បែរទៅប្រាប់កូនចៅរបស់ខ្លួនថា :

-នែ ! អារី, អារិន, សុខុម, ម៉ា, កាពៅ, ល្អិត ! រៀបចំខ្លួនប្រាណទៅ ... ទៅគេងជាមួយលោក

-ចាំម៉ែ !

នារីឆើតឆាយទាំង៧ឆ្លើយព្រមគ្នា ហើយក៏ដើរចេញទៅរៀបចំខ្លួនរៀងៗអាត្មា ។

ប្រហែលដប់នាទីក្រោយមក នារីទាំង៧ក៏ចេញមកវិញ ។ នាយ គុចនិងព្រឹល និយាយលេងជាមួយអ្នកយ៉ែមមួយម៉ាត់ពីរ ក៏សូមលា នាំនារីរាត្រីទាំង៧ឆ្ពោះមកកាន់សណ្ឋាគាររបស់ខ្លួន ។

អស់រយៈពេលពេញមួយរាត្រី នាយគុច នាយព្រឹលឥតបានដេកមួយស្រឡេតសោះ ។ ចំពោះនាយព្រឹល រាត្រីនេះគឺជារាត្រីដែលគេបានទទួលសេចក្តីសុខជាទីបំផុតក្នុងជីវិត ។

ព្រឹកឡើង នាយព្រឹលក្រោកពីគ្រែលែងរួច មុខស្លាំងហេវ ក្នុងខ្លួនគ្មានកម្លាំងកំហែងចំណីចំណុកប៉ះដល់មាត់ល្វីងចត់ទាំងអស់ ។ នាយ គុច បានដាស់ឱ្យចុះទៅក្រោមរកស្រស់ស្រូបកាហ្វេ គុយទាវ តែនាយ យើងគ្រវីក្បាលបដិសេធ ម៉្លោះហើយនាយគុចក៏ចុះទៅក្រោមបាត់ទៅទុកឱ្យនាយយើងដេកក្រៀមអាចម៍ភ្នែកម្នាក់ឯងនៅលើសណ្ឋាគារ ។

ប្រហែលជាម៉ោង១២ថ្ងៃត្រង់ នាយគុច ចុះទៅខាងក្រោមក៏មិនទាន់ឃើញត្រឡប់មកវិញ ។ នាយព្រឹលភ្ញាក់ម្តងទៀតខំប្រឹងទប់អាត្មា ក្រោកពីដេកទាំងពិបាក ។ ដើរទៅលុបមុខ សិតសក់រួចក៏មកអង្គុយចាំមើលផ្លូវ នាយគុចនៅមាត់ទ្វារ ។ ភាពដ៏អស្ចារ្យកាលពីយប់មិញ នៅកន្ត្រាក់អារម្មណ៍មិនទាន់ភ្លេច នាយនឹកឃើញដល់រឿងនេះឡើង សម្បុរគឹង្គក់ព្រឺព្រួចសារជាថ្មី ។

ចាំបាត់ ! ចាំបាត់ ! មិនឃើញនាយគុចត្រឡប់មកវិញ

នាយព្រឹលនឹកអផ្សុក ណាដូចជាឃ្លានបាយផង ក៏ដើរទៅយកកាបូបប្រាក់រាប់ចំនួនមើល តើសល់ប៉ុន្មានអស់ប៉ុន្មាន ? លូករាវក្នុងហោប៉ៅសព្វអស់ស្រាប់តែបាត់កាបូប បែរទៅមើលនាលិកាលើក្បាលគ្រែក៏បាត់ទៀត នាយព្រឹល ត្រជាក់ខ្លួន ធ្លាក់ថ្លើមក្តុកដឹងថាអាអ្នកលេង គុចសម្លាញ់រួមស្រុកវាវៃហើយ ។ ពេលនេះ សេចក្តីសប្បាយរីករាយទាំងប៉ុន្មាន អន្តរធានចេញពីខ្លួន

នាយព្រឹលអស់រលីងគ្មានសល់ នាយចេះនឹកស្រុក, ឪពុកម្ដាយ, គូសង្សារ ហើយក៏នឹកបន្ទោសខ្លួនឯង មិនគួរណាប្រហែសឱ្យនាយគុចលួចប្រាក់បានដូច្នេះ ។

ចៅមាណពក្បាលទំពែក អង្គុយសំរក់ទឹកភ្នែកតក់ៗ ឧទានតិចៗចេញមកទាំងអស់សង្ឃឹម :

-អាគុចអើយអាគុច ...! អាមិនគួរដាច់ចិត្តលួចលុយអញសោះ អញខំប៉ាវផឹកស៊ីស្រីញីប៉ុណ្ណឹងហើយ ឯងនៅមិនអាណិតអញទៀត ឯងលួចលុយអញគ្មានបន្សល់អីតិចតួច សូម្បីតែអាក្រដាសចាយមិនកើត ក៏ឯងយកដែរ ឱពុទ្ធោៗអើយ ... នេះហើយកម្មផលខ្ញុំ ... ម៉ែ ! ឪ ! កូននឹកម៉ែនឹកឪណាស់ តែទៅស្រុកវិញយ៉ាងម៉េចនឹងរួច បើគ្មានលុយមួយកាក់ឥចឹង ... អូនធឿន ... ម្ល៉េះសមអូនមើលផ្លូវបងយ៉ាងណាទៅ ... បងនៅចាំរូបអូនជានិច្ច តែ ...បងគ្មានលុយជិះឡានទៅស្រុកវិញទេ ប្រហែលជាដាច់ពោះស្លាប់នៅស្រុកគេហើយអូន

នាយព្រឹលកំពុងតែអង្គុយយំសោកាពិលាបក៏ឮសូរគោះទ្វារ :

-តុក ! តុក ! តុក ! ...

នាយព្រឹល យកដៃជូតទឹកភ្នែក ក្រោកទៅបើកទ្វារអររខិបរខុប ស្មានថាប្រហែលជានាយគុចត្រឡប់មក តែ ... ខុសស្រឡះអ្នកដែល ចូលមកមិនមែននាយគុចទេ គឺជាបោយបំរើសណ្ឋាគារទៅវិញ :

-អាលោក ! អា ... លោកមោនៅជិតឡប់ង៉ៃហើយ អាសៃហ៊ូអ៊ី ឱ្យសុំគិតលុយមួយឡងហា ! ទីងអស់ ...

បោយរាប់ក្រដាសគិតប្រាក់ឈ្នួលប្រចាំថ្ងៃមួយសន្ទុះ ក៏និយាយថា :

-ទីងអស់ វ៉ាបាំបីង៉ៃ មួយពាន់បីរយសាមសិបពីររៀល !

នាយព្រឹលគ្រាន់តែឮបោយប្រាប់ថានៅខ្វះថ្លៃឈ្នួលបន្ទប់ដេក ជាងមួយពាន់រៀល ក៏ស្រែកយំខ្លាំងៗ ដូចកូនក្មេងឱនទៅក្រាបសំពះ បាទជើងបោយសុំសេចក្ដីអនុគ្រោះ :

-ឱ ! អាហៀអើយ ... សូមអាណិតមេត្តាកុំយកឈ្នួលបន្ទប់អី ខ្ញុំឥឡូវនេះគ្មានប្រាក់មួយសេនទេ អាពួកម៉ាកខ្ញុំវាលួចអស់ទៅហើយ ខ្ញុំរកតែ៧០រៀលជិះឡានត្រឡប់ទៅស្រុកវិញក៏គ្មានផង ...

-មីងបាងទេ ! មិងបាងទេ ! ឃាមមីងឡឹងទេ ចាំអាសៃហ៊ូអី មោអុីយាយមួយអុីទៅ !

ថាហើយ បោយសណ្ឋាគារក៏រត់ប្រញាប់ទៅប្រាប់ស្មៀនប្រចាំសណ្ឋាគារ

មួយសន្ទុះក្រោយមក បោយអំបាញ់មិុញក៏ត្រឡប់មក បន្ទប់នាយ ព្រឹលវិញ នាំទាំងស្មៀនសណ្ឋាគារនិងភ្នាក់ងារប៉ូលិសក្រុងម្នាក់មកជាមួយផង ។

-គិតយ៉ាងម៉េចទៅរឿងឈ្នួលបន្ទប់ដេក មានលុយឱ្យខ្ញុំទេ ?

ស្មៀនសណ្ឋាគារ សួរទៅនាយព្រឹល ។

-ប្របាទ ! អត់ទេលោកថៅកែ ... សូមលោកថៅកែអាណិត ជួយស្រោចស្រង់សត្វលង់ទឹកផង

នាយព្រឹលឆ្លើយព្រមទាំងលើកដៃសំពះស្មៀន :

-អត់យ៉ាងម៉េចកើត ! ( ស្មៀនសម្លុត ) ពីយប់មិុញខ្ញុំឃើញ នាំស្រីមកដេកប្រាំមួយប្រាំពីរនាក់ ក៏ចេះមានលុយឱ្យ ត្រង់ឈ្នួលបន្ទប់ខ្ញុំ ម្ដេចក៏ឆ្លើយថាអត់ ! បើថាអត់មែនខ្ញុំឱ្យប៉ូលិសនាំទៅបកឥឡូវហ្នឹង !

ម្តងនេះ នាយព្រឹលកាន់តែភ័យមុខស្លាំង ដៃជើងញ័រទ្រើតៗ ដូចមាន់ធ្លាក់ទឹកព្រឹកព្រហាម :

-លុយខ្ញុំកាលមកពីស្រែមានលោក តែព្រឹកមិញនេះពួកម៉ាកខ្ញុំ វាលួចអស់ទៅ សូមលោកអាណិតមេត្តាខ្ញុំផង ...

-មិនបានទេ ! បើអ្នកឯងគ្មានលុយឱ្យខ្ញុំ ខ្ញុំត្រូវតែប្តឹងអ្នកឯង ចង់ដោះស្រាយយ៉ាងម៉េចៗ ទៅដោះស្រាយមុខលោកគុម្មិស៊ែរឯស្នងការដ្ឋានទៅ

ស្មៀននិយាយជាមួយនាយព្រឹលរួចហើយ ក៏បែរទៅនិយាយ ជាមួយភ្នាក់ងារប៉ូលិស :

-ឥឡូវខ្ញុំសូមប្តឹងសែហ្វពីម្នាក់នេះ ក្នុងបទជួលបន្ទប់សណ្ឋាគារខ្ញុំដេកហើយគ្មានលុយបង់ សូមសែហ្វអញ្ជើញនាំខ្លួនយកទៅចុះ ។

បន្ទាប់មកនាយព្រឹល ក៏ត្រូវភ្នាក់ងារប៉ូលិសចាប់ខ្លួននាំយកទៅស្នងការដ្ឋាន ។

.............................................................................

លោកនាយកស្នងការដ្ឋាន បានសាកសួរចម្លើយកត់ហេតុពីនាយ ព្រឹលសព្វគ្រប់ ដោយយល់ឃើញថានាយព្រឹលជាមនុស្សសុច្ចរិតស្លូតត្រង់ ល្ងង់ខ្លៅមិនដែលមកភ្នំពេញ ហើយត្រូវគេលួចប្រាក់អស់មែន ។ លោកនាយស្នងការអនុញ្ញាតឱ្យនាយព្រឹលរួចទុក្ខទោស ។ ប្រាក់ឈ្នួលបន្ទប់សណ្ឋាគារជាងមួយពាន់រៀលលោកចេញឱ្យគ្រប់ចំនួន ហើយឱ្យនាយព្រឹល ២០០រៀលក្រៅទៀតធ្វើសោហ៊ុយត្រឡប់ទៅស្រែវិញ ។

-នែ ! ថ្ងៃក្រោយបើអូនមកលេងភ្នំពេញ យើងមិនស្គាល់ទីក្រុងច្បាស់ ត្រូវរកអ្នកណាជាទីទំនុកចិត្តជូនមក កុំចេះតែជឿតាមមនុស្សបោកប្រាស់ឮទេ កុំស៊ីជោរឆ្កួតនឹងស្រីសំផឹងទៀតឱ្យសោះ អូនឯងជាប់បក ពីព្រោះអី ? គឺព្រោះតែសេពគប់មិត្តអាក្រក់ ឈ្លក់វង្វេងនឹងស្រីសំផឹង ថ្ងៃក្រោយសូមកុំលង់ខ្លួនខ្វះថ្លៃឡានឥចឹងទៀតណាស់ហើយ ! អញ្ជើញទៅចុះ

-ប្របាទ ! ប្របាទមិនបំភ្លេចគុណព្រះតេជគុណអស់មួយជីវិត

នាយព្រឹលចេញពីស្ថានការដ្ឋាន ដើរដំរង់ទៅបេនឡានរករថយន្តទៅស្រែវិញជាបន្ទាន់ក្នុងថ្ងៃនោះ ។

ក្រមុំខ្វារក កម្លោះស្លូឈាម

ចាំបាត់យូរថ្ងៃមិនឃើញមក ចិត្តស្រីនឹកភ្នកឃ្លានស្នេហា
ចំលើដើងបោកប៊ុនវោហារ ស្រីឆ្កួតតណ្ហាចុះតាមភ្លាម ។
អានោះរៀបរាប់នឹងចេញយក្ស ឪម៉ែគេភ្ញាក់ស្រែកគំរាម
នាយព្រឹលដឹងរឿងស្ទើរក្អួតឈាម ឡើងដើមព្រឹងភ្លាមប្រុងចងក

សូមអស់លោកអ្នកអានជាទីគោរព បែរដួងចក្ខុក្រឡេកមកមើលឃុំព្រៃស្វាយ ឯស្រុកស្រែម្តងវិញ ។ មីងព្រាបបាត់ដំណឹងកូនកម្លោះយូរក៏កើតក្តីព្រួយបារម្ភ គាត់អង្គុយមិនសុខ ដើរមិនស្រួលក្រវល់ក្រវាយក្នុងចិត្តម៉្ងៃ១ អង្គុយចាំមើលដើងឡានភ្នំពេញចង់ផ្សាភ្នែក ។

ចាំបាត់ ! ចាំបាត់ ! ... បីថ្ងៃ, បួនថ្ងៃ, ប្រាំថ្ងៃ, ប្រាំមួយថ្ងៃនៅតែមិនឃើញស្រមោលកូនត្រឡប់មក មីងព្រាបក៏អង្គុយនិយាយពិគ្រោះ ជាមួយពូព្រើលថា :

-ពុកវាអើយ ...! អាព្រើលកូនយើងទៅភ្នំពេញម្ដេចក៏ក្រមកម្លេះ ខ្ញុំចេះតែនឹកភ័យៗខ្លាចក្រែងវាវង្វេងវង្វាន់ដាច់ពោះស្លាប់ទេ ពីព្រោះខ្ញុំសួរអ្នកគេធ្លាប់ទៅ គេថាភ្នំពេញធំណាស់ ដើរលេងបីបួនខែមិនទាន់សព្វកន្លែងផងណា មួយថ្ងៃរៀបការក៏កាន់ តែខិតចូលមកជិតវរៗ វាមកមិនទាន់អីស្លាប់ខ្ញុំហើយមួយពេលនេះ ។

-ហ៊ឺ ! ពិបាកណាស់ ... (ពូព្រើលដកដង្ហើមធំជួយព្រួយភរិយា) អញកាត់មិនបានស្មានមិនយល់ទេ រឿងអាព្រើលនេះ ! ហាមហើយហាមទៀតហើយទៀត ហាមថាកុំឱ្យវាទៅភ្នំពេញ ចេះតែមិនជឿអញ ដល់បាត់ដំណឹងក៏នាំគ្នាកើតទុក្ខដូច្នេះឯង ។

ពូព្រើលនិយាយរួចមូរបារីស្លឹកសង្កែជក់បង្ហុយផ្សែងទ្រលោម ទៅលើអាកាស ហាក់ដូចជាកំពុងគិតពីរឿងអ្វីម្យ៉ាង ។ មួយសន្ទុះធំ ក្រោយមកទើបពូគាត់និយាយថា :

-បើតាមគំនិតអញយល់ អាព្រើលវាមិនមែនវង្វេងវង្វាន់ទេ អានេះបែបដើររកទិញរូបថតបង្រៀនវិធីស្នេហាមិនទាន់បានហើយមើលទៅ ចាំមើលវាពីរបីថ្ងៃទៀតមើល៍ ! បើវានៅតែបាត់ស្រមោល ចាំអញ ឡើងឡានទៅភ្នំពេញ តាមរកវា !

-ណាស់ហើយកុំនិយាយ ! ( មីងព្រាបរាដៃ ) ខ្លួនឯងមិនស្គាល់ភ្នំពេញ បែរមុខទៅខាងណាផង សង្ឃាចង់ទៅតាមកូន តិចពិបាកចោលឆ្អឹងស្រុកគេឱ្យខ្ញុំមេម៉ាយទៅ !

-យ៉ ! ឯងក៏មើលងាយអញខ្លាំងដៃម្ល៉េះ ! ស្មានតែអញហ្នឹងល្ងង់គ្រប់ដប់មិនដែលស្គាល់ភ្នំពេញដូចឯងសោះឬ? អញប្រាប់ឱ្យដឹង ! កាល អញនៅពីក្មេងអញធ្លាប់ទៅតាមលោកម្តងដែរ ទើបនឹងខានជាងសែសិបឆ្នាំទេ តើ ហា ! ហា ! ហា !

ពូព្រើលថាហើយក៏សើចបន្ធូរអារម្មណ៍ ។

មីងព្រាប នឹកខឹងនឹងសំដីនិយាយមែនលាយលេង គាត់បែរមុខ ចេញពីប្តី សម្លឹងមើលទៅលើមេឃ លើកដៃបន្ទូលលើក្បាលអធិដ្ឋាន ខ្លាំងៗថា :

-ឱ ! គុណព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ព្រះធកម្មាដែលមាន មហិទ្ធិឫទ្ធិខ្លាំងក្លាលើទ្វីបលោកទាំងបួនអើយ ...! សូមព្រះអង្គអាណិត មេត្តា ករុណាប្រណី ដល់កូនខ្ញុំម្ចាស់ សូមឱ្យវាធ្វើដំណើរទៅទីក្រុងម្តងនេះបានជួបភពប្រសប់តែនឹងជោគលាភ ចង់រកអ្វីប្រាថ្នាអ្វីឱ្យបានដូចសេចក្តីប៉ុនប៉ង សត្រូវមកពីមុខរលាយមកពីក្រោយរលត់ កុំបីមានជម្ងឺ ដំកាត់ឬគ្រោះកាចដោយប្រការណាមួយ មកពារធាលើខ្លួនប្រាណវាបានឡើយ ....

ពោលចប់ អ្នកមីងឱនសំពះមេឃបីដង បែរមកសម្លក់ពូព្រើល បន្តិចទើបក្រោកក្រេសដើរចូលទៅក្នុងផ្ទះបាយដណ្តាំស្ល ទុកឱ្យពូឃើងអង្គុយបៀមបារីស្លឹកសង្កែបង្ហុយផ្សែងខ្មោលៗទៅលើអាកាសតែឯកឯង ។

រាត្រីនេះឃុំព្រៃស្វាយស្ថិតនៅក្នុងសភាពស្ងាត់ជ្រៀប ។ ធាតុអាកាសត្រជាក់គ្របដណ្តប់ពាសពេញក្រឡាប្រថ ពីខ្យល់ជំនោរពីទិសព្វាសានបក់បោកមកមិនដាច់រយៈ ។ មនុស្សម្នាសម្ងំពួនរងារតត្រុននៅក្នុងផ្ទះ បង្កប់នូវសេចក្តីស្រួលស្រេីបព្រឺព្រួចរៀងរាល់អាត្មា ។

នាងធឿនយប់នេះដេកមិនលក់ ក្នុងទ្រូងតឹងតែងក្តៅក្រហាយ រកអធិប្បាយមិនត្រូវ ម្តងងាកមុខទៅឆ្វេងម្តងងាកមុខ ទៅស្តាំបំរះលាន់ព្ធសូរប្រូស ! ប្រាស់ ! ពេញតែលើគ្រែ ។ នាងនៅចាំច្បាស់មិនទាន់ភ្លេច ពាក្យនាយព្រឹល សូមលានាងទៅភ្នំពេញ ទិញឥវ៉ាន់ការបីថ្ងៃ ឥឡូវហួសកំណត់ច្រើនទិវាទៅហើយ ក៏នៅតែមិនទាន់លេចមុខប្រុសឆោមយង់មកទៀត ។ ថ្ងៃអាពាហ៍ពិពាហ៍ក៏ កាន់តែខិតចូលមកជិត បើដល់ថ្ងៃការ នាយព្រឹលមិនទាន់មកតើឱ្យនាងទៅអង្គុយផ្ទឹមការជាមួយអ្នកណាទៅ? ឱ្យពន្យាពេលអាក់ខានសិនឬ ? អូ ! មិនបានទេ ! ភ្លើងស្នេហ៍កំពុងឆាប ឆេះដូចគេដុតភ្លើងព្រៃយកអណ្តើកដូច្នេះហ៊ានតែខកខានមិនបានការ ថ្ងៃ១៣កើត ខែកក្តិកខាងមុខនេះ មុខជាប្រេះបេះដូងចេញឈាម ហៀរកខ្លាក់ហើយ ។

នាងធឿន បើកបង្អួចគន់មើលទៅព្រះចន្ទនាថ្ងៃ១០កើត ពន្លឺឆ្លុះចាំងមកក្នុងបន្ទប់ភ្លឺព្រាល១ ធ្វើឱ្យនាងបានសប្បាយរសាយពីទុក្ខព្រួយបន្តិច។ ស្រស់ស្រីសម្លឹងមើលទៅដើមពោធិ៍ក្នុងរង្វង់ព្រះចន្ទ ហើយក៏នឹកទៅដល់អនុស្សាវរិយ៍ ស្គាល់គ្នាគ្រាដំបូងនៅក្រោមដើមព្រីង។ នាង របូតមាត់តិច១ចេញមកថា:

-ខែអើយៗ អើយខែ ... ! ម្ដេចក៏ខែចាំមានដើមពោធិ៍នៅរង្វង់ចំកណ្ដាលធ្វើអ្វី ? ឱ ... ! នេះប្រហែលជាខែសើចចំអកឡុកឡឺយ ដាក់ខ្ញុំដោយដឹងថា ខ្ញុំធ្លាប់អង្គុយសារសងជាមួយបងព្រឹលហើយមើលទៅ ...!

នាងធឿន ឈប់ស្ងៀមបន្តិច បង្វិលខ្លួនបង្អួតនឹងរស្មីចន្ទ្រា ពើងទ្រូងទៅមុខ យកដៃរលាស់សក់ជូនសើច ជូនធ្វើមុខមាំដូចខឹងសម្បារ រួចពីហ្នឹងក៏ដើររាំក្បាច់ពត់ពែនពេញបន្ទប់ ។ ពុំមាននឹកខ្លាចក្រែងអ្នកណាម្នាក់លបឃើញកាយវិការវិកលចរិកនេះឡើយ ។

នៅក្រោមដើមក្រខុបក្បែរបន្ទប់នាងធឿនដេក ស្រមោលខ្មៅស្គុងមួយសម្ងំពួនលួចលបមើលកាយវិការនាងធឿនយ៉ាងយកចិត្តទុកដាក់អស់រយៈពេលជាច្រើនម៉ោងមកហើយ ។ នាងធឿនពុំបានដឹងខ្លួន ក៏តាំងបន្តសំដីទៀត :

-ខ្យល់ខែកត្តិកម្ដេចក៏ត្រជាក់ជាងសព្វខែម្ល៉េះ ? អូ ! យ៉ាងនេះហើយតើ ... បានជាចាស់ៗគាត់ដឹងចិត្ត គាត់រៀបការទុកដាក់កូនចៅ តែខែកត្តិក ពីព្រោះខែនេះវាត្រជាក់គួរឱ្យព្រឺព្រួចគួចចិត្តស្នេហាមែន... អ្នកតាក្រហមអើយ ... សូមឱ្យបងព្រឹលឆាប់វិលមកវិញមក ! នៅតែបីថ្ងៃទៀតទេ ដល់ថ្ងៃចូលរោងការបើអ្នកតាជួយខ្ញុំបាន ខ្ញុំនឹងថ្វាយក្បាលជ្រូកមួយឱ្យសេពសោយ ... បើបងព្រឹលមកមិនទាន់ទេ ខ្ញុំមិនដឹងបានអ្នកណាមករៀបការជំនួស មុខតែបោលចោលស្រុក រត់តាមប្រុសដទៃហើយ ... ខ្ញុំចង់បានប្ដីណាស់ ពេលយប់យន់ទន់ត្រជាក់ដូច្នេះធ្វើម្ដេច នឹងមាន ប្រុសប្រាណឯណាគេមកលួងលោមថ្នាក់ថ្នមខ្ញុំទៅហ្ន៎ ....

នាងធឿនទើបនិយាយផុតមាត់ សម្លេងបុរសចម្លែកឈរក្រោយ ដើមក្រខុបក៏សងវាចាមកនាងវិញតាមសសៃខ្យល់ព្យួររើយៗថា :

-ឱ ! កែវឆវីនារីរតនី បងឈរស្តាប់មាត់ស្រីយូរហើយ លុះដឹងចិត្តជាក់ទើបហ៊ានឆ្លើយធឿនអើយចុះមករកបងវ៉ា ...

នាងធឿនភ្ញាក់ព្រើតដូចគេកន្ត្រាក់ នឹកអៀនអន់តាមនិស្ស័យ ស្រីក្រមុំតែចិត្តមួយមកនឹកឃើញថាមានតែពីរនាក់ ហើយយប់ស្ងាត់ផង នាងក៏អន់ខ្មាស់ក្លែងវាចាសួរទៅវិញថា :

-អ្នកឯងជាមនុស្សដូចគេឯង ឬជាខ្មោចព្រាយបីសាច ? បានជាក្លាហាន ហ៊ានឆ្លើយឆ្លងសងសំដីជាមួយកូនក្រមុំគេកណ្តាលរាត្រី ស្ងាត់ដូច្នេះ !

-បងជាមនុស្សទេអូនពិសី នាងកុំខ្លាចអីចុះដីមក
បងដឹងថាអូនកើតទុក្ខសោក ទើបបងស្កាត់រកកែវជីវ៉ា
បងជួយថ្នាក់ថ្នមលោមមាសចិត្ត ព្រោះដឹងថាអូនជិតរៀបការ
ម្តេចឡើយចាំបាច់សួរតវ៉ា ឬមួយកនិដ្ឋាមិនទុកចិត្ត ។
អាព្រឹលនិងបងស្គាល់គ្នាជាក់ ធ្លាប់រៀនរួមថ្នាក់យ៉ាងជិតស្និទ្ធ
វាផ្តាំឱ្យបងជួយអាណិត ឱ្យជួយបង្ហាត់ក្បួនស្នេហា ...

-អ៊ុំ ! បងហ្នឹងជាមិត្តភ័ក្រ្តនឹងបងព្រឹលឬ ?

-ត្រូវហើយអូន ! បងជាមិត្តនិងអាព្រឹល !

-ចុះបងឈ្មោះអ្វីទៅ ប្រាប់ខ្ញុំឱ្យស្គាល់ផងបានទេ !

-មិនចាំបាច់សួរទេពៅពន្លក ឱ្យតែអូនចុះមកប្រាកដជាស្គាល់ ហើយ !

នាងធឿនឮដូច្នោះ លាត់សំពត់ចងក្បិនយ៉ាងតឹងសំរូតចុះមកសំដៅទៅរកបុរសរាត្រី នឹកកោតសរសើរតែក្នុងចិត្តថា : អ្នកណាគេនេះ អេះ ? ក៏ប៉ិនទាំងវោហារកំណាព្យកាព្យឃ្លោងម្លេះ ? សំដីសំដៅទៀត សោតក៏ផ្អែមល្ហែមប្រហែលជាមុខមាត់ស្អាតបាតណាស់ហើយមើលទៅ ។

នាងធឿនដើរទៅដល់ជិតក៏ភ្ញាក់ព្រើត ដោយស្គាល់ជាក់ជាកូនប្រសាមេស្រុកគាំ ។

-យី ៗ ហ្នងសនទេឬ ?

-ត្រូវហើយ ! កុំមាត់ខ្លាំងអូន ប្រាកដជាបងហើយកុំសង្ស័យទៀត ។

-បងឯងមកឈរធ្វើអ្វីថ្មើរហ្នឹង ?

-បងមកវរកអូនតាមបណ្ដាំអាព្រឹល !

អន្ទិតសននិយាយហើយក៏ទាញដៃនាងធឿនឱ្យអង្គុយចុះ ផ្អែកនឹងគល់ក្រខុប តែនាងបេះដៃចេញ ច្រត់ចង្កេះសួរទៅវិញថា :

-បងព្រឹល !... គាត់ផ្ដាំផ្ញើនឹងបងសនឯងយ៉ាងម៉េចខ្លះ និយាយប្រាប់ខ្ញុំមកមើល ?

-វាផ្ដាំនឹងបងថា បើពេលណាវាមិននៅ ឱ្យបងមកជួយថែរក្សា អូនផងហើយវានិយាយទៀតថា ម៉ែវាក៏ដូចម៉ែបង ប្រពន្ធវាក៏ដូចជា ប្រពន្ធបងដែរ....!

នាងធឿនហេតុតែជាស្រីក្រមុំល្ងង់ដប់គត់ ក៏លង់ចិត្តជឿតាម សំដីអន្ទិតសនស្លុង សមពេលនេះនាងកំពុងត្រូវការរកគូនៃបនិត្យផ្ចិតឱរ៉ា ស្រាប់ផងក៏ពុំ

បាននឹកសង្ស័យឬនឹកខ្មាស់អៀនថាខ្លួនជាស្រីក្រមុំព្រហ្មចារីយ៍ មិនគួរណាចុះមកជួបប្រុសឈ្មោលកណ្តាលអាធ្រាត្រស្ងាត់ឡើយ ។

អន្ទិតសនបានដៃ ឃើញនាងធឿននៅស្ងៀមក៏ចាប់ឱបរិតផ្តួលប្រាណទាំងជំហរទៅលើវាលស្មៅក្បែរគុលក្រខុបនឹកក្នុងចិត្តថា ម្តងនេះមុខជាបានសងសឹកនឹងនាយព្រឹលវិញហើយ ។

-អូនធឿនអាំ ...!

-ចាំ ... បងសន ... !

-អូនឯងជាតិនេះអភ័ព្វណាស់ បានប៉ះលើប្តីក្បាលទំពែក មនុស្សយ៉ាងអាព្រឹលមិនគួរណាអូនទៅស្រឡាញ់វាទេ ...

នាងធឿនភ្លើងកាមរាគៈកំពុងឆេះក្នុងទ្រូងក្តៅគគុក ក៏បង្ហើបមាត់សួរទៅនាយសនទាំងភ្នែកមមីរដូចមនុស្សស្រវឹងកញ្ឆាថា :

-ចុះមនុស្សរបៀបណាទៅដែលអូនគួរស្រឡាញ់ ...?

-នៅជិតៗអូនហើយតើ ចាំបាច់ឱ្យបងប្រាប់ចំដល់ណាទៀត ។

-អូ ! បងហ្នឹងឬ ? (នាងធឿនធ្វើជាភ្ញាក់) ខ្ញុំមិនហ៊ានស្រឡាញ់ ទេ ខ្ញុំជិតរៀបការហើយ ណាមួយបងក៏មានប្រពន្ធ លោតែមីរ៉ានដឹងខ្ញុំ លួចប្តីវា វាមិនលីពូថៅទាំងកណ្តាលថ្ងៃត្រង់មកពុះចំពាក់កណ្តាលដើមទ្រូងខ្ញុំហើយឬ ?

អន្ទិតសនសើចតិចៗ លូកដៃទៅច្របាច់សុដន់នាងធឿន បណ្តាលឱ្យនាងឡើងសម្បុរគីង្គក់ព្រឺខ្នាកៗមួយរំពេច :

-អូនឯងនៅខ្លាចដល់ណាទៀត ( អន្ទិតសននិយាយ ) អាព្រឹលប្រហែលជាវាឈ្លក់វង្វេងស្រីភ្នំពេញហើយ បានជាបាត់ដំណឹង ! អូនឯងទ្រាំចាំវាប្រយ័ត្នរងាររបេះដូងកកឈាមស្លាប់ណា៎ ...!

-ចា៎ះ ...! អូនជឿបងហើយ តែសូមបងប្រាប់មីរ៉ែនកុំឱ្យវាវាយខ្ញុំណា៎ គឺខ្ញុំការជាមួយបងព្រឹលផង ស្រឡាញ់បងសនឯងផងតចឹងស្រួលទេ ? ពីព្រោះវាត្រូវនឹងបណ្តាំបងព្រឹលគាត់ផ្តាំបងថា ម៉ែគាត់ដូច ម៉ែបង ! ប្រពន្ធគាត់ដូចប្រពន្ធបង ដូច្នេះខ្ញុំសង្សារបងដែរ កាលណាបង ព្រឹលធ្វើបាបខ្ញុំៗ ទៅជាមួយបង ហើយបើបងសនឯងធ្វើបាបខ្ញុំៗ មកនៅជាមួយបងព្រឹលវិញ ។

អន្ទិតសននឹកពេញចិត្តនឹងសំដីល្ងង់ខ្លៅរបស់នាងធឿន គេគិតថាពេលនេះជាឱកាសល្អហើយ ដែលគេគួរតែបង្ខំរួមរ័ក្សជាមួយនាងឱ្យទាល់តែសំរេចដើម្បីជាកិច្ចផ្តន្ទាទោសចំពោះអំពើដែលនាយព្រឹលចិត្តធំ ថ្លើមពាសមេឃ ហ៊ានលបឡើងផ្ទះទាំងយប់ ទៅមើលខ្លួនកំពុងបង្រៀន វិធីស្នេហាដល់ប្រពន្ធ ។

អន្ទិតសនចិត្តពាល លិទ្ធមាត់លិទ្ធកបោលសំរុកទាំងបិទភ្នែកជិត ថើបក្រញ៉ីញក់ញីលើខ្លួនប្រាណនាងធឿនគ្មានត្រាប្រណី រឹងដៃខំប្រឡេះឡេវអាវយ៉ាងប្រញាប់ ។ នាងធឿនមិនធ្លាប់អ្នកណាធ្វើរបៀបនេះមកពីមុន ក៏បេះនាយសនចេញ ក្រោកអង្គុយឱបក្បាលជង្គង់ឱ្យផ្អប់នឹងដើមទ្រូងជាប់ :

-ឈប់សិនបងសន ! បងឯងគិតធ្វើអីខ្ញុំហ្នឹង ...!

-ដោះអាវចេញទៅអូន ...!

-ទេ ! ខ្ញុំមិនដោះទេ ! រងារចង់ស្លាប់ទៅហើយ ដោះធ្វើអី ?

អន្ទិតសននឹកស្រងាកចិត្តកាលបើមិនបានសមបំណង ។ ឈប់ដកដង្ហើមឱ្យបាត់ហត់បន្តិច នាយពាលក៏ប្រឹងនិយាយលួងលោមទៀត :

-មនុស្សយើងកាលណាគេស្រឡាញ់គ្នាគេត្រូវតែដោះអាវ ចេញទើបសន្មតថាយើងចិត្តស្មោះត្រង់នឹងគ្នាណ៎ាអូន ...

នាងធឿនគ្រវីក្បាលមិនព្រម :

-ទេ ! ខ្ញុំមិនដោះអាវទេ ! រងាររណ្ដំថ្កាមយ៉ាងនេះសមតែពាក់អាវប្អូនដប់ជាន់ គ្រលំភួយពីរបី ឱ្យដោះអាវចេញអស់រលីងបងឯងមិនចេះរងារទេឬ ?

អន្ទិតសនអស់ផ្លូវនឹងពន្យល់នាងធឿនឱ្យដោះអាវបាន អ្នកក៏នឹកឃើញមធ្យោបាយថ្មីមួយទៀតបំរុងនឹងចាប់ផ្ដើមអនុវត្តន៏ស្រាប់តែ !...

-កាធឿន ! អើ ... កាធឿន ! យី ! ចុះកូននេះវាទៅណា ...?

សម្លេងមីងឡឹកស្រែកប្រកួកមកទៀត ។

នាងធឿនភិតភ័យរកព្រលឹងព្រលះគ្មាន មិនដឹងគិតយ៉ាងណា ក៏ធ្វើជាប្រះខ្លួនដេកលក់ក្បែរគល់ក្រខុបនោះទៅ ទុកឱ្យពូញ៉ៅ មីងឡឹក ស្រែកប្រកួកហៅស្អកកតែពីរនាក់ ។

មួយសន្ទុះមក ភ្លើងចន្លុះពីរដើមក៏ទ្រោលមកជិតកន្លែងនាង ធឿនដេក ។ ពូញ៉ៅមីងឡឹក ឃើញជាក់ជាកូនក្រមុំគាត់ហើយក៏ម្ទីម្ទា ចាប់អង្រួនឱ្យភ្ញាក់

-នែ ! កាធឿន ! ម៉េចក៏ឯងមកដេកក្រោមដើមក្រខុបទៅវិញ ?

មីងឡឹកសួរ ។

នាងធឿនគ្រវីក្បាលធ្វើភ្នែកម៉ក់ៗ ស្វាបហាវមាត់មួយចង្អាម ដូចនៅមិនទាន់ស្វាងងងុយ បែរជាសួរបញ្ច្រាសស្រដីទៅម្ដាយវិញថា :

-ព្រឹកហើយឬម៉ែ ?

-អើ ! ហ្នឹងបានចំជាប្រាំពីរសន្ដាន អញសួរថាយ៉ាងម៉េចបានជាដេក នៅក្នុងបន្ទប់សុខៗ ប្រកាច់មកនៅឯណេះទៅវិញ ?

-អូ ! យី ! (នាងធឿនបើកភ្នែកធំៗ ធ្វើជាទើបនឹងភ្ញាក់ដឹងខ្លួន )ខ្ញុំអត់ដឹងខ្លួនឯងថាមកដេកក្រោមដើមក្រខុបហាល ខ្យល់សន្សើមឥចឹង ទេម៉ែអើយ ...!

-ឥចឹងមានតែឯងដេកមមើល ?

-ចា៎ ! ប្រហែលហើយម៉ែ!

នាងធឿនឆ្លើយចាក់បណ្ដោយតាម ។

ពូញៀជឿឥតសង្ស័យ គាត់ប្រញាប់និយាយទៅកាន់ប្រពន្ធថា :

-នាំវាទៅលើផ្ទះភ្លាមៗទៅ ! មនុស្សដេកមមើមមាយអត់ដឹងខ្លួនប្រាណឥចឹង ទាល់តែស្អែកយកទៅវត្តឱ្យលោកស្រោចទឹកហើយ អានេះពាក្យចាស់គេហៅថាបិសាចកន្លង កាលអញនៅពីកម្លោះដូចវាម្ដងដែរ ! អញមមើស្រាតខោដើរកាត់ស្រែពីរ ស្រែបីទាល់តែខ្មោចពុកគាត់ យកទៅស្រោចទឹកធ្វើខ្សែចង្កេះឱ្យពាក់ទើបបានបាត់ ! ...

-ហ៊ឺ ...! សព្វៗ ហើយកាធឿនអើយ កាធឿន ! ...

មីងឡឹករអ៊ូរទាំ ហើយក៏ដឹកដៃនាងធឿនដើរនាំមុខពូញៀឡើងទៅលើផ្ទះវិញ ។

ព្រឹកស្អែកឡើង ...

ខណៈដែលពូព្រើលមីងព្រាប កំពុងអង្គុយពិគ្រោះគ្នាពីរឿងបាត់ដំណឹងកូនកម្លោះនៅយ៉ានហាលខាងមុខផ្ទះ ក៏ស្រាប់តែលេចមុខនាយព្រើលពើមមក

មីងព្រាបស្ទុះចុះពីលើផ្ទះទៅទទួលកូនត្រេកអររខិបរខុប តែគាត់មកនឹកចម្លែកចិត្តត្រង់មុខនាយព្រើលមិនស្ងវស្រស់បស់ ហើយគ្មានឃើញកាន់កញ្ចប់បញ្ចប់ជាប់ដៃអ្វីមកបន្តិចបន្តួចសោះ ។ ឡើងអង្គុយលើផ្ទះស្រួលបួល មីងព្រាបក៏ចាប់ផ្តើមសាកសួរថា :

-ម្តេចក៏ទៅភ្នំពេញអីយូរថ្ងៃម្ល៉េះកូន ម្តាយខំចាំមើលផ្លូវឯងរាល់ថ្ងៃឡើងផ្សាភ្នែក ហើយម៉េចក៏មុខមាត់ក្រៀមក្រោះតចឹង ? ឯងឈឺឬ ? ឯណាតវ៉ាន់ទិញមករៀបការ ?

នាយព្រើលមិនឆ្លើយតបនឹងសំនួរម្តាយ បែរជាស្រែកយំខ្លែង១ ហៀរទឹកភ្នែកទឹកសម្បោរដូចកូនក្មេង ។ មីងព្រាបមិនដឹងរឿងហេតុ ឃើញកូនយំខុសទំនងក៏រិតតែភ័យបញ្ឈរភ្នែក ។ ពូព្រើលស្មារតីរឹង ប្រញាប់សួរទៅកូនថា :

-រឿងហេតុអីបានជាឯងយំ ? និយាយប្រាប់អញឱ្យដឹងផងមើល ?

-បាទពុក ! ( នាយព្រើលនិយាយអណ្តឺតអណ្តក់ ) ខ្ញុំ ...ខ្ញុំ ...ចាញ់បោកអាគុចមួយចានស្រឡះ ... ! ទៅលេងភ្នំពេញរិះជាប់គុកខាន ឃើញមុខឪម៉ែ ...ខ្ញុំអត់លុយជិះឡានមកវិញទេ ... បើកុំបានលោកគុម្ពស៊ើរឱ្យថ្លៃឡាន ប្រហែលជាដេកអត់បាយស្លាប់ស្រុកគេហើយពុកអើយ ...

-វាយ៉ាងម៉េចតចឹង ! ក្រែងឯងទៅពីនេះយកប្រាក់មួយម៉ឺនទៅដែរអី !

ពូព្រើល សួរទៅកូនកម្លោះដោយងឿងឆ្ងល់ ។

នាយព្រើលលើកជាយអាវជូតទឹកភ្នែកឱ្យស្ងួត ហើយក៏និយាយរ៉ាយរាប់រឿងរ៉ាវប្រាប់ទៅឪពុក ៖

-កាលអាគុចវានាំខ្ញុំទៅដល់ភ្នំពេញ វាជួលបន្ទប់ផ្ទះសំណាក់មួយនៅក្បែរផ្សារថ្មីឱ្យខ្ញុំឈប់សំណាក់ ម៉ែៗវានាំខ្ញុំដើរលេងគ្រប់ច្រកល្ហក វាបញ្ឆោរខ្ញុំឱ្យប៉ាវវាស៊ីចាយដូចជាកូនមហាសេដ្ឋី មានល្ងាចមួយ វាបង្អកស្រាខ្ញុំទាល់តែស្រវឹងលែងដឹងខុសត្រូវ វាឱ្យខ្ញុំទៅស្គាល់បនស្រីសំផឹង អំណាចស្រាធ្វើទុក្ខខ្ញុំក៏ជ្រុលខ្លួនជាមួយពួកមីអស់នោះមួយយប់ទើសភ្លឺ ទៅលុះព្រលឹមឡើងអាគុចលួចប្រាក់ខ្ញុំរត់បាត់លែងយល់ស្រមោល ម្ចាស់ផ្ទះសំណាក់មកទារថ្លៃបន្ទប់ដល់ខ្ញុំឆ្លើយថាអត់ គេក៏ប្ដឹងប៉ូលិសឱ្យចាប់ខ្ញុំទៅបក ទំរាំលោកគុម្មិស្សែរ សាកសួររកខុសត្រូវ ខ្ញុំជាប់ឃុំអស់កន្លះព្រឹក ដែលខ្ញុំមានលុយជិះឡានមកផ្ទះវិញនេះ គឺលោកឱ្យប្រាក់ខ្ញុំទេ នឹកៗទៅខ្ញុំឈឺចិត្តនឹងអាគុចបោកប្រាស់ ចង់តែលោតពីលើផ្ទះឱ្យបាក់កស្លាប់ឥឡូវទេពុក ! ...

ពូព្រើលស្ដាប់ពាក្យកូនបរិយាយ រួចដកដង្ហើមធំ គ្រវីក្បាល នឹកឆ្អែតចិត្ត ៖

-ហ៊ឺប្រាក់ក៏បង់ថង់ក៏ដាច! ឈប់កើតទុក្ខព្រួយទៅ កុំទៅគិតចង់សម្លាប់ខ្លួនអីណ៎ា! អស់ប្រាក់មួយម៉ឺនរៀលទុកដូចជាម៉ែឯងគេ ចាញ់កន្ទុយលេខសៀមមួយចានទៅចុះ !

-នែ ! ឱ្យវាល្មមៗទៅលោកបងព្រើល ! កុំបាច់និយាយដាក់ផ្លែ ដាក់ផ្កាដៀមដាមមកដល់ខ្ញុំណ៎ា !

មីងព្រាបស្រែកគំហកឱ្យប្ដី ដោយខឹងនិយាយរឿងកន្ទុយលេខ ៖

-រឿងកូនចៅធំប៉ុនភ្នំមិនគិតដោះស្រាយ ! បែរជាយករឿងឯង លេងកន្ទុយលេខពីឆ្នាំពោរកំបោរឯណាមកនិយាយទៅវិញ ត្រូវដឹងថា ជញ្ជាំងមានត្រចៀកណា៎ ! តិចពិបាកចូលគុកអស់ទាំងសំបុក ! ...

-ហា ! ហា ! ហា ! ( ពូព្រើលសើច ) ឥឡូវឯងចេះខ្លាចគុកច្រវាក់ដែរឬ ? បើឯងចេះតែរបៀបនេះប៉ុន្មានឆ្នាំមុន មិនមែនអាសេង លីវាំងជញ្ជូនប្រាក់ទៅធ្វើផ្ទះថ្មកំពស់ភ្នំសំពៅបាត់ដំបងទេ ណាស់ហើយឈប់និយាយទៀតទៅ ! អញថ្លង់ត្រចៀកណាស់

-អើ ! វាមកតែពីកញ្ចាស់ក្បាលឯងហ្នឹងនាំអញនិយាយមុនអញឈប់ប្រព្រឹត្តឈប់នឹកនាមកយូរហើយតើ !

មីងព្រាបបើកភ្នែកក្រឡោត១ ជំដែកបែកពពុះមាត់មិនព្រមចុះចាញ់ប្តី

បរិយាកាស ស្ថិតនៅក្នុងសភាពស្ងប់ស្ងាត់មួយខណៈ បន្ទាប់មកពូព្រើលក៏ប្រែបទសន្ទនា និយាយទៅកាន់នាយព្រីលថា :

-ទៅរកងូតទឹកងូតភក់ទៅកូន ! ឯងឈប់ព្រួយចិត្តទៀតណាអាណិតតែឪពុកផងទៅចុះ នៅពេលតែបីថ្ងៃទៀតដល់ថ្ងៃចូលរោងការ ហើយល្ងាចត្រជាក់បន្តិចល្មមទៅលេងផ្ទះមីនាងធឿនផង ឪពុកម្តាយគេ គេចាំមើលផ្លូវឯងសម្បើមណាស់ ...!

-បាទ ! ពុក ...

នាយព្រីល ឆ្លើយរួចក៏កំពៀកបង្វិចខោអាវ ក្រោកដើរចូលទៅខាងក្នុងផ្ទះបាត់ទៅ ។

.....................................................................

ល្ងាចត្រជាក់ ខ្យល់ធ្លាក់ពីទិសឧត្តរ បក់បោកផ្កាត្រែងឱ្យមានចលនារេរាំពត់ពេនដូចហ្វូងកិណ្ណរីលេងទឹកស្រះ ។

នៅគុម្ពោតព្រៃខាងលិចដើមព្រីងឯណោះ នាយព្រឹលនិង នាង ធឿន កំពុងអង្គុយសាកសួរសុខទុក្ខគ្នាដោយសភាពស្ងប់ស្ងាត់ កន្លែងនេះហើយជារមណីយដ្ឋានដែលអ្នកទាំងពីរផ្តួចផ្តើមផ្ញើពាក្យពេចន៍នឹងគ្នាគ្រា ដំបូង ។

-បងព្រឹលអ្ហា ... បងទៅភ្នំពេញទិញអ្វីបានខ្លះ ហើយម្តេចក៏យូរម្ល៉េះ អូននឹកស្មានថាបងឈ្លក់វង្វេងស្រីទីក្រុង ភ្លេចកាធឿនស្រីស្រុកស្រែ ហើយទេតើ...?

នាងធឿននិយាយរួច ក៏ផ្តេកក្បាលកើយភ្លៅប្រុសស្នេហ៍ដូចសព្វដង ។

-ហ៊ឺ ! (នាយព្រឹលដកដង្ហើមធំ ) រឿងបងទៅភ្នំពេញ តែនឹកឃើញឡើងកាលណា ចង់តែចងកសម្លាប់ខ្លួនទេអូន បើអូនស្រឡាញ់បងសូមចិត្តកុំឱ្យបងនិយាយល្អជាងបងក្តៅចិត្តណាស់ !

នាយព្រឹល ភ្នែករលីងរលោងរកកលចង់យំ ឈប់ស្ងៀមបន្តិច យកខ្នងដៃជូតទឹកភ្នែកស្អាត ទើបនិយាយតទៅទៀត :

-ពិតមែនតែខ្លួនបងឃ្លាតចេញឆ្ងាយ តែចិត្តបងនៅចងចាំមក លើរូបអូនគ្រប់ដង្ហើមដកចេញចូល ! ក្នុងជាតិនេះបងគ្មានស្រឡាញ់ស្រីណាក្រៅពីអូនទេ ... តើអូនមាននឹកដល់បង ដូចជាបងនឹកអូនទេ ?

-ចាំ ! ខ្ញុំនឹកបងដែរ ! កាលបងរៀបទៅភ្នំពេញ បងផ្តាំឱ្យបង សនប្តិមីរ៉ែនមកថែរក្សាខ្ញុំមែនទេ ?

-ថៃរក្សាយ៉ាងម៉េច ! ហ្អា ! ( នាយព្រឹលសួរទៅសង្សារស៊ើរចង់ទៅជាស្រែក ) វាធ្វើអ្វីអូនឯងខ្លះ ? បងស្បថឱ្យងាប់ឪម៉ែបងទៅចុះ ! បងមិនដែលមានពាក្យផ្ដាំផ្ញើអីវាទេ ! មើល ! អូនឯងនិយាយប្រាប់បងឱ្យត្រង់មកមើល៍ ! វាធ្វើអីអូនឯងខ្លះ ? វរៗ ខ្ទេចខ្ទក់បាយបិណ្ឌជាបាយបាត្រអស់ទៅហើយក៏មិនដឹង ?

នាងធឿន ត្រូវនាយព្រឹលសង្សុកខ្លាំងក៏ស្លន់ភ័យ ស្រក់ទឹកភ្នែកញ័រមាត់រកនិយាយលែងរួច បង្កើនឱ្យនាយព្រឹលកាន់តែសង្ស័យ ក្ដៅក្រហាយខ្លាំងទៅទៀត :

-អូនឯងនិយាយប្រាប់បងភ្លាមមក ! តើវាបានលួចប្លន់អ្វីពីអូនទៅខ្លះ ? អូនឯងនេះបានចំជាក្រមុំខ្វាក់រក ! គ្រាន់តែជិតដល់ថ្ងៃរៀបការទ្រាំចាំឱ្យដល់សិនមិនបាន ! បងដឹងរឿងហើយ ! អាសនវាធ្វើហ្នឹងគឺចង់ សងសឹកបងយើ ! អាសម្លាញ់កុំតែខ្លាចបែកការ កុំអីបានល្អមើលហើយអាភឿន !

និយាយចប់ នាយព្រឹលក៏ក្រោកឈរលាស់ដៃអាវ តាំងយុំគុន លោតល្បុក្កតោ ពេញគុម្ពោតព្រៃ ដោយកំហឹងក្រេវក្រោធមហិមា ។

រីឯនាងធឿន ព្រលឹងព្រលះចូលមកសន្ធិតក្នុងខ្លួនវិញសព្វគ្រប់ ក៏និយាយប្រាប់ទៅនាយព្រឹលថា :

-កុំអាលច្រឡោតខ្លាំងពេកបង ...! ចាំស្ដាប់ពាក្យអូននិយាយប្រាប់សិនរឿងហេតុទាំងប៉ុន្មានគឺខុសមកពីអូន ហើយដែលអូនប្រព្រឹត្តខុសនេះទៀតក៏មកពីសេចក្ដីល្ងង់ខ្លៅ ...

-អើ ! អាឆ្នាតអាល្ងង់បងមិនដឹងទេ បងសូមសួរដោយខ្លីថាវាបានធ្វើអីខ្លះ ?

-ចា៎ះ គាត់បានឱប !

-អៃយ្យូយ ! ស្លាប់អញហើយ ... !

នាយព្រឹលភ្លាត់មាត់ ប្រញាប់សួរបញ្ជាក់ថែម :

-ដល់ឱបហើយយ៉ាងម៉េចទៀត

-ចា៎ ! គាត់ថើប ...

-វ៉ាស់ !!! អានេះបានចំកៅឌី ! តែប៉ុណ្ណោះស្រេចហើយ !

នាយព្រឹលរលាស់ដៃចេញពីសង្សារ រត់សំដៅទៅឡើងដើម ព្រីងយកក្រមាចងកខ្លួនឯងចងភ្ជាប់នឹងបង្គាបមែកព្រីងបំរុងលោតសម្លាប់ខ្លួន ។

នាងធឿន ឃើញដូច្នោះខ្លាចសង្សារស្លាប់ ភ័យមុខឡើងស្វាយ លើកដៃសំពះនាយព្រឹលពីក្រោមដើមព្រីង និយាយអង្វរថា :

-បងព្រឹលកុំទាន់លោត ! ចាំស្តាប់ពាក្យអូនឱ្យចប់ចុងចប់ដើមសិន ! បងសនគាត់ថើបហើយគាត់ច្របាច់ដោះ ផុតពីច្របាច់ដោះ ទៅគ្មានអីទៀតទេ ពីព្រោះពេលនោះឪនិងម៉ែគាត់ភ្ញាក់ ស្រែករកអូន បងសនក៏បោលចូលព្រៃបាត់ទៅ !

នាយព្រឹលឈប់ទ្រឹង ដៃកាន់ក្រមាទ្រង់គិតមួយសន្ទុះទើបហារមាត់សួរមកនាងធឿនថា :

-បើឥចឹង ! ក្រៅពីថើប, ច្របាច់ដោះ, ប្រាកដជាគ្មានអ្វីលើសពីហ្នឹងពិតមែនឬ ?

-ចាំ ! អត់ទេបង ... ! ឱ្យអូនស្បថដល់ណាក៏ហ៊ានដែរ ។

-អើ ! បើពិតដូចពាក្យថា អាហ្នឹងវានៅកែកុនបានឈប់ភ័យទៅបង មិនលោតទេ !

ថាហើយនាយព្រឹលក៏សំរូតចុះពីលើមែកព្រីងមកដីវិញ ។

នាងធឿន អរស្ទុះទៅឱបនាយព្រឹលញញឹមចេញមកទាំងទឹក ភ្នែកនៅហូររហាម :

-រឿងកន្លងហួសមកហើយសូមបងកុំយកវាធ្វើជាអារម្មណ៍ ការអ្វីទាល់តែធ្វើខុសម្តងទើបរកត្រូវឃើញ ឥឡូវយើងទៅផ្ទះវិញបង កុំឱ្យម៉ែគាត់ចាំមើលផ្លូវ ។

-ទៅក៏ទៅ ! តែឱ្យបងសុំថើបមួយខ្សឺតសិន !

-ហក ! ថើបទៅ ...!

នាងធឿន ហុចថ្ពាល់ឱ្យនាយព្រឹលថើប ។ លុះថើបរួចហើយ ! អ្នកទាំងពីរក៏នាំគ្នាដើរមកផ្ទះវិញ បាត់ទុក្ខ បាត់ព្រួយតាំងពីពេលនោះ ។

បីថ្ងៃក្រោយមក ពិធីរៀបមង្គលការរវាងអ្នកកម្លោះព្រឹល និងនាងកញ្ញាធឿនក៏បានរៀបចំធ្វើឡើងយ៉ាងគគ្រឹកគគ្រេងអធឹកអធ៍ម ។ ភ្ញៀវក្រមុំកម្លោះចាស់ទុំក្នុងស្រុក បានមកជូនសព្ទសារធុការពរដល់យុវស្វាមីភរិយានេះគ្រប់ៗគ្នា ។ អន្ទិតសនក៏ត្រូវគេអញ្ជើញមកក្នុងពិធីនេះដែរ តែហាក់ដូចជាមិនសូវរីករាយសប្បាយដូចភ្ញៀវទៀតៗសោះ ។

-ចប់-